ព្រះរាជក្រម

នស/រកម/១០០៧/០២៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខគខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាថនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៤/១២៤ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងពិធីសារឆ្នាំ១៩៧២ ដែលបានធ្វើវិសោធនកម្មអនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ ១៩៦១ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE

12-10-07

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួម ក្នុងពិធីសារឆ្នាំ ១៩៧២ ដែលបានធ្វើវិសោធនកម្ម អនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ ១៩៦១

មាត្រា ១.-

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងពិធីសារឆ្នាំ ១៩៧២ ដែលបានធ្វើវិសោធនកម្មអនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ ១៩៦១ ធ្វើនៅទីក្រុងហ្សឺណែវ នាថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៧២ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តពិធីសារនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆកររ

នរោត្តម សីហមុនី

ត.ស.ល.០៧១០.៥៣៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង

លេខ: ៤៩១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ហ៊ុន ជិនកេន

អនុសញ្ញាទោល

ស្តីពី

គ្រឿងញៀន ឆ្នាំ ១៩៦១

ដូចដែលបានធ្វើវិសោធនកម្មដោយពិធីសារ ឆ្នាំ ១៩៧២ ដែលបានកែប្រែអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១

រួមបញ្ចូល តារាង ច្បាប់ និងសេចក្តីសំរេចចុងក្រោយ ដូចបានព្រមព្រៀង ដោយសន្និសីទរបស់អង្គការសហប្រជាជាតិឆ្នាំ ១៩៦១ សំរាប់ការអនុម័តអនុសញ្ញាទោល ស្តីពី គ្រឿងញៀន និងដោយសន្និសីទរបស់អង្គការសហប្រជាជាតិ ឆ្នាំ ១៩៧២ ដើម្បីពិចារណាលើការធ្វើសោធនកម្មចំពោះអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ ។

អង្គការសហប្រជាជាតិ

ច្បាប់ចុងក្រោយនៃសន្និសីទរបស់អង្គការសហប្រជាជាតិ
សំរាប់ការអនុម័តអនុសញ្ញាទោល
ស្តីពី
គ្រឿងញៀន

១- តាមរយៈសេចក្តីសំរេចលេខ ៦៨៩ J (XXVI) ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៥៨ ក្រុមប្រឹក្សាសង្គម និងសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិបានសំរេចកោះប្រជុំ ដោយអនុលោមទៅតាមមាត្រា ៦២ កថាខ័ណ្ឌទី៤ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ហើយដោយយោងទៅតាមបទបញ្ញត្តិនៃសេចក្តីសំរេចរបស់មហាសន្និបាតលេខ៣៦៦(IV) ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៤៩ សន្និបាតពេញអង្គសំរាប់ការអនុម័តនៃអនុសញ្ញាទោលស្តីពីគ្រឿងញៀន ដើម្បីជំនួសដោយលិខិតទុបករណ៍ទោលមួយ ការមានសន្និសញ្ញាពហុភាគីក្នុងការអនុវត្តន៍ ដើម្បីកាត់បន្ថយនូវចំនួនសន្និសញ្ញាអន្តរជាតិដែលទាក់ទងទៅនឹងការត្រួតពិនិត្យគ្រឿងញៀន ហើយដើម្បីបង្កើតបទបញ្ញត្តិសំរាប់ត្រួតពិនិត្យផលិតផលនៃវត្ថុធាតុដើមគ្រឿងញៀន។

២- សន្និសីទអង្គការសហប្រជាជាតិសំរាប់ការអនុម័តអនុសញ្ញាទោល ស្តីពីគ្រឿងញៀន បានជួបប្រជុំគ្នានៅទីបញ្ជាការរបស់អង្គការសហប្រជាជាតិ ចាប់ពីថ្ងៃទី ២៤ ខែមករា រហូតដល់ ២៥ ខែមីនា ឆ្នាំ១៩៦១ ។

៣- បណ្តារដ្ឋទាំង ៧៣ ខាងក្រោមនេះបានបញ្ជូនតំណាងរបស់ខ្លួនឱ្យចូលរួមក្នុងសន្និសីទមាន :

ប្រទេស

Afghanistan
Albania
Argentina
Australia
Bolivia
Brazil
Bulgaria
Burma
Byelorussian Soviet So-
-cialist Republic
Cambodia
Canada
Chad
Chile
China
Congo (Leopoldville)
Costa Rica
Greece
Guatemala
Haiti
Holy See
Hungary
India
Indonesia
Iran
Iraq
Israel
Italy
Japan
Jordan
Korea, Republic of
Lebanon
Liberia
Madagascar
Paraguay
Peru
Philippines
Poland
Portugal
Romania
Senegal
Spain
Sweden
Switzerland
Thailand
Tunisia
Turkey
Ukrainian Soviet Socialist
Republic
Union of Soviet Socialist
Republics

Czechoslovakia	Mexico	United Arab Republic
Dahomey	Monaco	United Kingdom of
Denmark	Morocco	Great Britain and
Dominican Republic	Netherlands	Northern Ireland
El Salvador	New Zealand	United States of America
Finland	Nicaragua	Uruguay
France	Nigeria	Venezuela
Germany, Federal Re-	Norway	Yugoslavia
-public of	Pakistan	
Ghana	Panama	

៤- ប្រទេសមួយខាងក្រោមនេះ បានបញ្ជូនអ្នកសង្កេតការម្នាក់អោយចូលរួមក្នុងសន្និសីទ គឺប្រទេស Ceylon

៥- ភ្នាក់ងារជំនាញពិសេសដែលបានចូលរួមក្នុងសន្និសីទនោះ រួមមាន : អង្គការកសិកម្មម្ហូបអាហាររបស់អង្គការសហប្រជាជាតិ អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ អង្គការពលកម្មអន្តរជាតិ និងអង្គការសុខភាពពិភពលោក ។

៦- អង្គការតំណាងអន្តរជាតិ ដែលមានវត្តមាននៅក្នុងសន្និសីទនោះរួមមាន :
គណៈកម្មការកណ្តាលអចិន្ត្រៃយ៍ប្រឆាំងនឹងអាភៀន
អង្គការត្រួតពិនិត្យគ្រឿងញៀន

៧- អង្គការក្រៅរដ្ឋាភិបាលដែលមានវត្តមាននៅក្នុងសន្និសីទនោះរួមមាន:
អង្គការសន្និសីទសប្បុរសធម៌កាតូលិកអន្តរជាតិ អង្គការប៉ូលីសព្រហ្មទណ្ឌអន្តរជាតិ អង្គការសហព័ន្ធមេធាវីស្ត្រីអន្តរជាតិ ។

៨- ឧត្តមសេនីយ៍ Safwat, នាយកការិយាល័យប្រឆាំងគ្រឿងញៀនអចិន្ត្រៃយ៍របស់សម្ព័ន្ធមិត្តអារ៉ាប់ ក៏បានចូលដោយផ្ទាល់តាមរយៈការអញ្ជើញរបស់សន្និសីទនោះផងដែរ ។

៩- យោងទៅតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និង សង្គម ដោយអនុលោមទៅតាមកថាខ័ណ្ឌ ១ និងជាមួយវិធាននីតិវិធីដែលបានអនុម័តដោយសន្និសីទនោះ អ្នកសង្កេតការណ៍ និងអ្នកតំណាងរបស់អង្គការដែលបានរៀបរាប់ខាងលើ និងអង្គការតំណាង ដែលបានចូលរួមនៅក្នុងការងារសន្និសីទ គ្មានសិទ្ធិបោះឆ្នោតទេ ។

១០-សន្ធិសីទនោះបានបោះឆ្នោតសំរេចអោយលោក Carl Schurmann (Netherlands) ធ្វើជាប្រធាន ហើយជាអនុប្រធាន អ្នកតំណាងនៃប្រទេសខាងក្រោមនេះ :

Afghanistan	Peru
Brazil	Switzerland
Dahomey	Thailand
France	Turkey
Hungary	United Arab Republic
India	United Kingdom of Great Britain and Northern Ireland
Japan	Union of Soviet Socialist Republics
Mexico	United States of America
Pakistan	

១១- លេខាធិការប្រតិបត្តិរបស់សន្ធិសីទនោះ គឺលោក G.E. Yates, និង លេខាធិការប្រតិបត្តិរង គឺលោក Adolf Lande.

១២- ដោយយោងទៅតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម សន្ធិសីទមានសេចក្តីព្រាងលើកទី៣នៃអនុសញ្ញាទោល ស្តីអំពីគ្រឿងញៀនដែលបានរៀបចំឡើង ដោយគណៈកម្មការ ស្តីអំពីក្រុមប្រឹក្សាគ្រឿងញៀន និងភាពស្មុគស្មាញនៃការអធិប្បាយដែលមាននៅទីនេះ ព្រមទាំងមានឯកសារដទៃទៀត១ផងដែរ នៅចំពោះមុខដែលបានរៀបចំឡើងដោយអគ្គលេខាធិការ ។

១៣- សន្ធិសីទនោះ បានបង្កើតឡើងនូវគណៈកម្មាធិការដូចតទៅ :

គណៈកម្មការទូទៅ

ប្រធាន : ប្រធានសន្ធិសីទ

គណៈកម្មាធិការពិសេស ដែលមានចែងនៅក្នុងមាត្រា ២ និង មាត្រា ៣ នៃសេចក្តីព្រាងទី៣ នេះ (ទំហំរបស់សន្ធិសីទ និងវិធីសាស្ត្រ នៃការនាំសារធាតុបន្ថែមក្រោមការត្រួតពិនិត្យ) ។

ប្រធាន : លោក A-Tabibi (Afghanistan)

គណៈកម្មាធិការពិសេស ដែលមានចែងនៅក្នុងមាត្រា ២៥. ៣០ និង ៤០-៤៣ (និយាយរួម ការត្រួតពិនិត្យថ្នាក់ជាតិ)

ប្រធាន : លោក B. Banerji (India)

គណៈកម្មាធិការពិសេសដែលមានចែងនៅក្នុងមាត្រា ៣១-៣៤ (ការត្រួតពិនិត្យដើមអាកៀនស្រស់ និង ដើមអាកៀនសួតថ្នាក់ជាតិ)

ប្រធាន : លោក L.Ignacio-Pinto (Dahomey)

អនុប្រធាន :លោក J.Koch (Denmark)

គណៈកម្មាធិការពិសេសដែលមានចែងនៅក្នុងមាត្រា ៣៥-៣៨ (ការត្រួតពិនិត្យស្លឹកកូកាថ្នាក់ជាតិ)

ប្រធាន: លោក K.Chikaraishi (Japan)

គណៈកម្មាធិការពិសេសដែលមានចែងនៅក្នុងមាត្រា ៣៩ (ការត្រួតពិនិត្យកញ្ឆាថ្នាក់ជាតិ)

ប្រធាន : លោក B.Grinberg (Bulgaria)

គណៈកម្មាធិការពិសេសដែលមានចែងនៅក្នុងមាត្រា ២៦, ២៧-២៩, ២០-២១, ៤ (និយាយរួម ពតិមានត្រូវបានគេផ្តល់អោយ តាមរយៈរដ្ឋាភិបាល ប្រព័ន្ធប៉ាន់ស្មាន និង ស្ថិតិ កាតព្វកិច្ចរបស់រដ្ឋាភិបាល)

ប្រធាន : លោក I.Rodriguez Fabregat (Uruguay)

អនុប្រធាន: លោក J. Bertschinger (Switzerland)

គណៈកម្មាធិការពិសេសដែលមានចែងនៅក្នុងមាត្រា២២ (វិធានការ ដែលយកមកអនុវត្តន៍ ដោយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ នៅក្នុងករណីមិនធ្វើតាម)

ប្រធាន : លោក A.Gurinovich (Byelorussian SSR)

គណៈកម្មាធិការពិសេសដែលមានចែងនៅក្នុងមាត្រា ៥-១១, ១៣-១៩, ២៣ (រដ្ឋធម្មនុញ្ញ មុខងារ និង លេខាធិការអង្គការអន្តរជាតិ)

ប្រធាន: លោក H.Blomstedt (Finland)

គណៈកម្មាធិការពិសេសដែលមានចែងនៅក្នុងមាត្រា ៤៤-៤៦ (វិធានការដោយផ្ទាល់ប្រឆាំងនឹងការរត់ពន្ធ ខុសច្បាប់)

ប្រធាន : លោក A.Bittencourt (Brazil)

គណៈកម្មាធិការបច្ចេកទេស

ប្រធាន : លោក A.Johnson (Australia)

អនុប្រធាន : លោក A. Ismael (United Arab Republic)

គណៈកម្មាធិការពង្រាង

ប្រធាន : លោក R.Curran (Canada)

អនុប្រធាន : លោក D.Nikolic (Yugoslavia)

គណៈកម្មាធិការសារតាំង

ប្រធាន :លោក G.Ortiz (Costa Rica)

១៤- ជាលទ្ធផលនៃការពិភាក្សារបស់ខ្លួន ដូចដែលបានកត់ចូលក្នុងកំណត់ត្រាសង្ខេប នៃសម័យប្រជុំពេញលេញ និងកំណត់ត្រាសង្ខេប ព្រមទាំងរបាយការណ៍របស់គណៈកម្មាធិការ សន្ធិសីទដែលបានអនុម័ត[1] និងបើកចំហសំរាប់ចុះហត្ថលេខាលើអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ ។ ក្រៅពីនោះ សន្ធិសីទបានអនុម័តទៅលើសេចក្តីសំរេច ៥ ដែលបានភ្ជាប់ដោយឧបសម្ពន្ធ័ទៅលើច្បាប់ចុងក្រោយនេះ ។

ដើម្បីទុកជាសាក្សី អ្នកតំណាងទាំងអស់បានចុះហត្ថលេខាលើច្បាប់ចុងក្រោយនេះ ។

ធ្វើនៅទីក្រុង ញ៉ូយក ថ្ងៃទី សាមសិប ខែ មីនា ឆ្នាំ មួយពាន់ប្រាំបួនរយហុកសិបមួយ ជាភាសា ចិនមួយច្បាប់ អង់គ្លេសមួយច្បាប់ បារាំងមួយច្បាប់ រុស្ស៊ីមួយច្បាប់ និង អេសស្បាញមួយច្បាប់ ដែលមានតំលៃដើមស្មើៗគ្នា ។ អត្ថបទដើម ត្រូវតំកល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

[1] សន្ធិសីទបានធ្វើការកត់សំគាល់ថា អនុសញ្ញាត្រូវបានអនុម័តដោយគ្មានលំអៀងចំពោះការសំរេចចិត្ត ឬ សេចក្តីប្រកាសនៅក្នុងសេចក្តីសំរេចរបស់មហាសន្និបាតដែលពាក់ព័ន្ធណាមួយ ។

សន្ធិសីទរបស់អង្គការសហប្រជាជាតិបានអនុម័តសេចក្តីសំរេច
សំរាប់ការអនុម័តនៃអនុសញ្ញាទោលស្តីពីគ្រឿងញៀន

សេចក្តីសំរេច I
ជំនួយបច្ចេកទេស ស្តីពីគ្រឿងញៀន

សន្ធិសីទ

ស្វាគមន៍ការបង្កើតឡើង សេចក្តីសំរេច លេខ ១៣៩៥ (XIV) ស្តីអំពី ការរៀបចំពិសេសសំរាប់ការផ្តល់ជំនួយបច្ចេកទេសក្នុងវិស័យ ត្រួតពិនិត្យគ្រឿងញៀនរបស់មហាសន្និបាត .

ដោយកត់សំគាល់ថា អង្គការសហប្រជាជាតិ និង ទីភ្នាក់ងារជំនាញដែលពាក់ព័ន្ធបានផ្តល់ជូនរួចហើយនូវជំនួយដោយមានកំណត់ តាមកម្មវិធីពង្រីកជំនួយផ្នែកបច្ចេកទេស និង កម្មវិធីធម្មតានានារបស់ពួកគេ.

ស្វាគមន៍ផងដែរនូវកិច្ចសហប្រតិបត្តិការរបស់អង្គការប៉ូលីសព្រហ្មទណ្ឌអន្តរជាតិ ក្នុងការអនុវត្តន៍គំរោងជំនួយបច្ចេកទេសនានា .

សំដែងនូវសេចក្តីសង្ឃឹមថា ត្រូវធ្វើអោយមានធនធានគ្រប់គ្រាន់ ដើម្បីផ្តល់ជំនួយក្នុងការប្រឆាំងនឹងចរាចរគ្រឿងញៀនដល់បណ្តាប្រទេសទាំងឡាយណាដែលមានបំណង និងស្នើនូវធនធានទាំងនេះ ជាពិសេសក្នុងក្របខ័ណ្ឌទីប្រឹក្សាជំនាញ និងការហ្វឹកហ្វឺនដោយរួមបញ្ចូលទាំង វគ្គហ្វឹកហ្វឺន សំរាប់មន្ត្រីជាតិ ។

សេចក្តីសំរេច II
ការព្យាបាលអ្នកញៀនគ្រឿងញៀន

សន្ធិសីទ

រំលឹកឡើងវិញនូវបទបញ្ញត្តិនៃមាត្រា ៣៨ នៃអនុសញ្ញាដែលពាក់ព័ន្ធ ការព្យាបាល និងការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

១- ប្រកាសថា វិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រដែលមានប្រសិទ្ធភាព ភាគច្រើននៃការព្យាបាលចំពោះការញៀន គឺជាការព្យាបាលក្នុងគ្រឹះស្ថានមន្ទីរពេទ្យមួយដែលមានបរិយាកាសគ្មានគ្រឿងញៀន ។

២- អំពាវនាវភាគីនានា ដែលមានបញ្ហាការញៀនគ្រឿងញៀនធ្ងន់ធ្ងរ និង មធ្យោបាយផ្តែកសេដ្ឋកិច្ចដើម្បី ធ្វើកិច្ចការទាំងអស់នេះ ព្រមទាំងផ្តល់នូវឧបករណ៍ទាំងនេះដែលចាំបាច់ ។

សេចក្តីសំរេច III

អ្នកជួញដូរខុសច្បាប់

សន្និសីទ

១- ផ្តោតការយកចិត្តទុកដាក់ទៅលើ សារៈសំខាន់នៃកំណត់ត្រាបច្ចេកទេស ស្តីអំពី អ្នករត់ពន្ធអន្តរជាតិ ដែលថែរក្សាទុកនៅពេលបច្ចុប្បន្ននេះ ដោយអង្គការប៉ូលីសព្រហ្មទណ្ឌអន្តរជាតិ ។

២- ផ្តល់អនុសាសន៍អោយគេបំពេញនូវកំណត់ហេតុទាំងនេះ ទៅតាមលទ្ធភាពដែលអាចធ្វើបានពីគ្រប់ភាគី ទាំងអស់ ហើយអោយប្រើប្រាស់យ៉ាងទូលំទូលាយ ដើម្បីចេញអោយប្រើនូវសេចក្តីអធិប្បាយ ស្តីអំពី អ្នករត់ពន្ធ ដោយអង្គការនោះ ។

សេចក្តីសំរេច IV

សមាជិកភាពនៃគណៈកម្មការ ស្តីពីគ្រឿងញៀន

សន្និសីទ

អញ្ជើញក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមអោយពិនិត្យមើលទៅលើបញ្ហានៃការកើនឡើងក្នុងសមាជិកភាព នៃគណៈកម្មការ ស្តីអំពី គ្រឿងញៀន ស្របទៅតាមអាណត្តិនៃអនុសញ្ញានេះ និង ទស្សនៈដែលបានបញ្ចេញ ទៅលើបញ្ហានេះ នៅក្នុងសន្និសីទនេះក្នុងសម័យប្រជុំលើកទី ៣២ របស់ខ្លួន ។

សេចក្តីសំរេច V

យន្តការត្រួតពិនិត្យអន្តរជាតិ

សន្និសីទ

ដោយយល់ឃើញ អំពីសារៈសំខាន់នៃការសំរួលដល់ការរៀបចំបណ្តោះអាសន្នដែលបានផ្តល់អោយ ដែលមានចែងនៅក្នុងមាត្រា ៤៥ នៃអនុសញ្ញាទោល ស្តីពីគ្រឿនញៀនៅក្នុងឆ្នាំ ១៩៦១ ។

អញ្ជើញក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមអោយចូលរួមសិក្សា ពីលទ្ធភាពនៃការចាត់វិធានការដែល ចានាបាននូវការអនុវត្តន៍យ៉ាងឆាប់រហ័ស និងរលូន ដើម្បីធ្វើអោយងាយស្រួលដល់យន្តការត្រួតពិនិត្យអន្តរ ជាតិ ។

ច្បាប់ចុងក្រោយនៃសន្និសីទរបស់អង្គការសហប្រជាជាតិ ដើម្បីពិចារណាទៅលើការធ្វើវិសោធនកម្ម ចំពោះអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១

១. ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ កត់សំគាល់ថា ការធ្វើវិសោធនកម្ម ត្រូវបានស្នើឡើង ចំពោះអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ និងការចងចាំនូវមាត្រា ៤៧ នៃអនុសញ្ញានោះ ដែលបានកំណត់ដោយសេចក្តីសំរេច លេខ ១៩៧៧ (L) ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៧១ ដើម្បី កោះប្រជុំសន្និសីទពេញអង្គមួយ ដើម្បីធ្វើការពិចារណាទៅលើការធ្វើវិសោធនកម្មទាំងអស់ ដែលបានស្នើ ឡើង ចំពោះអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ ដោយអនុលោមទៅតាម មាត្រា ៦២ កថា ខណ្ឌទី ៤ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ។

២. សន្និសីទរបស់អង្គការសហប្រជាជាតិ ដើម្បីពិចារណាទៅលើការធ្វើវិសោធនកម្មចំពោះ អនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ បានធ្វើឡើងនៅឯការិយាល័យរបស់អង្គការសហប្រជាជាតិ នាទីក្រុងហ្សឺណែវ ពីថ្ងៃទី ៦ ដល់ ២៤ ខែ មីនា ឆ្នាំ ១៩៧២ ។

៣. បណ្តារដ្ឋទាំង ៩៧ ខាងក្រោមនេះ បានបញ្ជូនតំណាងរបស់ខ្លួនឱ្យចូលរួមក្នុងសន្និសីទ :

Afghanistan	Haiti	Nigeria
Algeria	Holy See	Norway
Argentina	Hungary	Pakistan
Australia	India	Panama
Austria	Indonesia	Peru
Belgium	Iran	Philippines
Bolivia	Iraq	Poland
Brazil	Ireland	Portugal
Bulgaria	Israel	Republic of Korea
Burma	Italy	Republic of Viet-Nam
Burundi	Ivory Coast	Saudi Arabia
Byelorussian Soviet Socialist Republic	Jamaica	Senegal
Canada	Japan	Sierra Leone
Ceylon	Jordan	Singapore
Chile	Kenya	South Africa
Colombia	Khmer Republic	Spain

Costa Rica	Kuwait	Sudan
Cuba	Laos	Sweden
Cyprus	Lebanon	Switzerland
Czechoslovakia	Liberia	Thailand
Dahomey	Libyan Arab Republic	Togo
Denmark	Liechtenstein	Tunisia
Ecuador	Luxembourg	Turkey
Egypt	Madagascar	Ukrainian Soviet Socialist Republic
El Salvador	Malawi	Union of Soviet Socialist Republics
Federal Republic of Germany	Mexico	United Kingdom of Great Britain and Northern Ireland
Finland	Monaco	United States of America
France	Mongolian People's Republic	Uruguay
Gabon	Morocco	Venezuela
Gambia	Netherlands	Yugoslavia
Ghana	New Zealand	Zaïre
Greece	Nicaragua	
Guatemala	Niger	

៤. រដ្ឋ ដូចខាងក្រោមនេះ បានបញ្ជូនអ្នកសង្កេតការណ៍របស់ខ្លួនឱ្យចូលរួមក្នុងសន្និសីទ :

Cameroon	Malaysia	Romania
Dominican Republic	Malta	

៥. តាមរយៈសេចក្តីសំរេចលេខ ១៩៧៧ (L) ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម បានស្នើឱ្យអគ្គលេខាធិការ អញ្ជើញអង្គការសុខភាពពិភពលោក និងទីភ្នាក់ងារពិសេសដែលមានការពាក់ព័ន្ធផលប្រយោជន៍ផ្សេងៗទៀត គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ និង អង្គការប៉ូលីសព្រហ្មទណ្ឌអន្តរជាតិ ដើម្បីចូលរួមក្នុង សន្និសីទ ។ អង្គការសុខភាពពិភពលោក គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ និង អង្គការ ប៉ូលីសព្រហ្មទណ្ឌអន្តរជាតិ បានបញ្ជូនតំណាងរបស់ខ្លួនដើម្បីចូលរួមនៅក្នុងសន្និសីទ ។

៦. សន្និសីទ បានបោះឆ្នោតអោយលោក K. B. Asante (Ghana) ធ្វើជាប្រធាននៃសន្និសីទ Mr. D. Nikoli (Yugoslavia) ជាអនុប្រធានទី និង អនុប្រធានដទៃទៀត តំណាងឱ្យរដ្ឋដូចខាងក្រោមនេះ :

Argentina	Lebanon	United Kingdom of Great Britain and Northern Ireland
Egypt	Mexico	United States of America
France	Turkey	
India	Union of Soviet Socialist Republics	

៧. Mr. V. Winspeare-Guicciardi, អគ្គនាយកនៃការិយាល័យរបស់អង្គការសហរបជាជាតិ ប្រចាំនៅទីក្រុងហ្សឺណែវ គឺជាអ្នកតំណាងរបស់អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ ។ លេខាប្រតិបត្តិនៃសន្និសីទនេះ គឺ Dr. V. Kuševi, ទីប្រឹក្សាច្បាប់នៃសន្និសីទនេះ គឺលោក Mr. G. Wattles និងលេខាប្រតិបត្តិរង និងទីប្រឹក្សាច្បាប់រង គឺ Mr. P. Raton.

៨. សន្និសីទបានធ្វើមុន ការធ្វើវិសោធនកម្មចំពោះអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ដែលបានស្នើឡើងដោយរដ្ឋដែលបានចូលរួមនៅក្នុងសន្និសីទនេះ ។

៩. សន្និសីទ បានបង្កើតគណៈកម្មាធិការដូចតទៅ :

គណៈកម្មាធិការទូទៅ

Chairman: The President of the Conference

គណៈកម្មាធិការទី ។

Chairman: Dr. R. A. Chapman (Canada)

គណៈកម្មាធិការទី ॥

Chairman: Dr. Béla Bölcs (Hungary)

គណៈកម្មាធិការពង្រាង

Chairman: Mr. J-P, Bertschinger (Switzerland)

គណៈកម្មាធិការសាតាំង

Chairman: Mr. J. W. Lennon (Ireland)

១០. *គណៈកម្មាធិការទីមួយ ត្រូវបានបង្កើតក្រុមការងារមួយ ស្របតាមមាត្រា ១៤ ប្រធាននៃក្រុមការងារនោះ គឺលោក* A. C. Kirca (Turkey).

១១. ជាលទ្ធផលនៃការពិភាក្សារបស់ខ្លួន ដូចដែលបានកត់ត្រានៅក្នុងរបាយការណ៍សង្ខេបនៃសម័យប្រជុំពេញអង្គ និងគណៈកម្មាធិការទី ១ និង ទី ១១ សន្និសីទ បានអនុម័ត និងបើកចំហសំរាប់ការចុះហត្ថលេខាលើ

ពិធីសារនៃការធ្វើវិសោធនកម្មលើអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ ។ ជាងនេះទៅទៀត សន្ធិសីទ បានអនុម័តនូវសេចក្តីសំរេចបី ដែលភ្ជាប់ដោយឧបសម្ព័ន្ធទៅនឹងច្បាប់ចុងក្រោយនេះ ។

ធ្វើនៅទីក្រុង ហ្សឺណែវ ថ្ងៃទី ម្ភៃប្រាំ ខែ មីនា ឆ្នាំ មួយពាន់ប្រាំបួនរយចិតសិបពីរ ជាភាសា អង់គ្លេស មួយច្បាប់ បារាំងមួយច្បាប់ រុស្ស៊ីមួយច្បាប់ និង អេសស្បាញមួយច្បាប់ អត្ថបទនីមួយៗ មានតំលៃដើមស្មើៗគ្នា ។ អត្ថបទដើម ត្រូវតំកល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ដើម្បីទុកជាសាក្សី អ្នកតំណាង បានចុះហត្ថលេខាលើច្បាប់ចុងក្រោយនេះ ។

សន្ធិសីទរបស់អង្គការសហប្រជាជាតិ
បានអនុម័តសេចក្តីសំរេច ដើម្បីពិចារណាទៅលើការធ្វើវិសោធនកម្ម
ចំពោះអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១

សេចក្តីសំរេច I

លេខាធិការដ្ឋាននៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ

សន្ធិសីទ

ដោយពិចារណាថា វិធានការដែលបានអនុម័តដោយ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម នៅក្នុងសេចក្តីសំរេចរបស់ខ្លួន លេខ ១៩៩៦ (XLII) ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៦៧ (កិច្ចប្រជុំពេញអង្គលើកទី ១៩៦៤) បានធ្វើតាមបំណងប្រាថ្នានៃភាគីរដ្ឋទាំងអស់ចំពោះអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ និង ចំពោះអនុសញ្ញាមុនៗដែលនៅជាធរមាន ។

ផ្តល់សេចក្តីយល់ព្រមនូវការបន្តនៃប្រព័ន្ធដែលត្រូវបានអនុវត្ត ដោយអគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ និង ដែលជាបទប្បញ្ញត្តិសំខាន់ គឺមានដូចតទៅ :

១. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ(ដោយសំដៅទៅលើដូចជាគណៈកម្មាធិការ) មានលេខាធិការដ្ឋានមួយ ផ្សេងពីផ្នែកគ្រឿងញៀន.

២. លេខាធិការដ្ឋាននោះ គឺជាផ្នែកទាំងមូលនៃលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរដ្ឋបាលទាំងស្រុងរបស់អគ្គលេខាធិការ ដើម្បីអនុវត្តន៍សេចក្តីសំរេចរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តជាតិ.

៣. សមាជិកនៃលេខាធិការដ្ឋាន ត្រូវបានតែងតាំង ឬជ្រើសតាំងដោយអគ្គលេខាធិការ ប្រធាននៃលេខាធិការដ្ឋាននោះ ត្រូវបានតែងតាំង ឬជ្រើសតាំង ដោយការពិគ្រោះគ្នាជាមួយគ៌ណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ។

សេចក្តីសំរេច II

ថវិកាក្នុងការត្រួតពិនិត្យគ្រឿងញៀន

សន្ធិសីទ

ដោយនឹកឃើញថា ការផ្តល់ជំនួយទៅអោយប្រទេសកំពុងអភិវឌ្ឍន៍ គឺជាការបង្ហាញអោយឃើញយ៉ាងច្បាស់លាស់នូវឆន្ទៈរបស់សហគមន៍អន្តរជាតិ ដើម្បីទទួលយកនូវការប្តេជ្ញាចិត្តដែលមានចែងនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ដើម្បីជំរុញអោយមានការរីកចំរើនផ្នែកសេដ្ឋកិច្ច និងសង្គមរបស់ប្រជាជនទាំងអស់ ។

ដោយនឹងឃើញឡើងវិញ នូវការចាត់ចែងពិសេស ដែលធ្វើឡើងដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិ ដែលស្ថិតនៅក្រោមសេចក្តីសំរេច លេខ ១៣៩៥ (XIV) ជាមួយនិងការផ្តល់នូវជំនួយបច្ចេកទេសសំរាប់ការត្រួតពិនិត្យការប្រើប់ពានគ្រឿងញៀន.

ដោយទទួលស្គាគមន៍ចំពោះការបង្កើតឡើងនូវមូលនិធិរបស់អង្គការសហប្រជាជាតិ សំរាប់ត្រួតពិនិត្យការប្រើប់ពានគ្រឿងញៀន ដោយអនុលោមទៅតាមសេចក្តីសំរេចរបស់មហាសន្និបាតរបស់អង្គការសហប្រជាជាតិលេខ ២៧១៩ (XXV).

ដោយកត់សំគាល់ឃើញថា សន្និសីទបានអនុម័តមាត្រា ១៤ ស្ងួនថ្មីមួយ ដែលពាក់ព័ន្ធទៅនឹងជំនួយបច្ចេកទេស និងជំនួយហិរញ្ញវត្ថុ ដើម្បីបង្កើនការអនុវត្តន៍អោយកាន់តែមានប្រសិទ្ធភាពថែមទៀតនូវបទប្បញ្ញត្តិនៃអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ .

១. ប្រកាសថា ដើម្បីធ្វើឱ្យកាន់តែមានប្រសិទ្ធភាព វិធានការដែលបានធ្វើឡើងប្រឆាំងទៅនឹងការប្រើប់ពានគ្រឿងញៀន ត្រូវបានសំរបសំរួល និង ជាសកល ។

២. ប្រកាសទៀតថា ការបំពេញដោយប្រទេសកំពុងអភិវឌ្ឍន៍នូវភកាព្វកិច្ចរបស់គេ ដែលស្ថិតនៅក្រោមអនុសញ្ញា នឹងត្រូវសំរបសំរួលតាមរយៈជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ពីសហគមន៍អន្តរជាតិ ។

សេចក្តីសំរេច III

លក្ខខណ្ឌពិសេស និងការគាំពារប្រឆាំងទៅនឹងការញៀនគ្រឿងញៀន

សន្និសីទ

ដោយនឹងឃើញឡើងវិញថា បុព្វកថានៃអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ បញ្ជាក់ថា ភាគីទាំងអស់នៃអនុសញ្ញា គឺ "មានការព្រួយបារម្ភជាមួយនិងសុខភាព និងសុខុមាលភាពរបស់មនុស្សជាតិ និងមាន "មនសិការចំពោះភារកិច្ចរបស់ខ្លួន ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងទៅនឹងបិសាចនៃការញៀនគ្រឿងញៀន ។

ដោយពិចារណាឃើញថា ការពិភាក្សានៅឯសន្និសីទ បានផ្តល់នូវភស្តុតាងនៃបំណងប្រាថ្នា ដើម្បីចាត់វិធានការ អោយមានប្រសិទ្ធភាពចំពោះការទប់ស្កាត់ការល្បែងគ្រឿងល្បែង ។

ដោយពិចារណាឃើញថា គណៈពេលដែលការល្បែងគ្រឿងល្បែង ឈានទៅដល់ការធ្វើអោយថោកទាបរបស់ បុគ្គល និងការបង្កាក់សង្គម វាកើតឡើងជារឿយៗ នោះលក្ខណៈសេដ្ឋកិច្ច និងសង្គមមានការសោកស្តាយ ដែលក្នុងនោះ បុគ្គលជាក់លាក់ទាំងនោះ និងក្រុមជាក់លាក់ ដែលកំពុងរស់នៅ ជំរុញអោយពួកគេល្បែងគ្រឿង ល្បែង ។

ដោយទទួលស្គាល់ថា កត្តាសង្គម ពេលខ្លះ មានឥទ្ធិពលជាក់លាក់ និង ឧត្តមានុភាពទៅលើចរិតលក្ខណៈរបស់ បុគ្គល និងក្រុមទាំងនោះ ។

ផ្តល់អនុសាសន៍ថា ភាគីទាំងអស់ :

១. គួរចងចាំថា អ្នកល្បែងគ្រឿងល្បែង គឺតែងតែជាលទ្ធផលនៃបរិយាកាសសង្គមដែលមានគ្រោះ ថ្នាក់ ផ្ទៃកសុខភាព ដែលក្នុងនោះ អ្នកទាំងនោះ គឺទទួលរងនូវគ្រោះថ្នាក់នៃការរស់នៅដោយ ការប្រើប់ពានគ្រឿងល្បែង

២. គួរធ្វើរាល់អ្វីៗនៅពេលខ្លួនកាន់អំណាច ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងការរីករាលដាលនៃការប្រើ គ្រឿងល្បែងខុសច្បាប់ ។

៣. គួរអភិវឌ្ឍន៍នូវសកម្មភាពល៉ូហែ និងសកម្មភាពផ្សេងៗទៀតដែលនាំអោយមានសុខភាពផ្ទៃក ផ្លូវកាយ និងផ្លូវចិត្តដល់ឃុវវ័យ ។

អនុសញ្ញាទោល
ស្តីពី
គ្រឿងញៀន ឆ្នាំ ១៩៦១
ដូចដែលបានធ្វើវិសោធនកម្មដោយពិធីសារ ឆ្នាំ ១៩៧២
ដែលបានកែប្រែអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១

បុព្វកថា

ភាគីទាំងឡាយ

ដែលជាប់ពាក់ព័ន្ធទៅនឹងសុខភាព សុខុមាលភាពរបស់មនុស្សជាតិ ។

ដោយទទួលស្គាល់ថា ការប្រើប្រាស់គ្រឿងញៀនក្នុងវិស័យសុខាភិបាលបន្តប្រើជាចាំបាច់ដើម្បីបំបាត់ការឈឺចាប់ និងទុក្ខវេទនា ហើយបទបញ្ញត្តិគ្រប់គ្រាន់ត្រូវធ្វើឡើង ដើម្បីធានាអោយឃើញនូវថ្នាំញៀនសំរាប់គោលបំណងនោះ ។

ដោយទទួលស្គាល់ថា ការញៀនថ្នាំញៀន គឺជាគ្រោះថ្នាក់មួយដ៏ធ្ងន់ធ្ងរចំពោះបុគ្គលហើយគ្រោះថ្នាក់នេះក៏ជាផលប៉ះពាល់ធ្ងន់ធ្ងរដល់សេកិច្ចសង្គម និងមនុស្សជាតិផងដែរ ។

ដោយមានការយល់ដឹងអំពីភារកិច្ចរបស់ខ្លួន ដើម្បីការពារ និងប្រយុទ្ធប្រឆាំងនឹងគ្រោះថ្នាក់នេះ ។

ដោយចាត់ទុកថា វិធានការដ៏មានប្រសិទ្ធភាព ប្រឆាំងនិងការប្រើប្រាស់គ្រឿងញៀនតំរូវទោមទារអោយមានសកម្មភាពសហប្រតិបត្តិការជាសកលមួយ ។

ដោយយល់ឃើញថា សកម្មភាពជាសកលនោះ អំពាវនាវអោយមានកិច្ចសហប្រតិបត្តិការជាអន្តរជាតិ ដឹកនាំដោយគោលការណ៍តែមួយដូចគ្នា និងឆ្ពោះទៅរកគោលបំណងរួមតែមួយ ។

ដោយទទួលស្គាល់នូវសមត្ថភាពរបស់អង្គការសហប្រជាជាតិ ក្នុងវិស័យត្រួតពិនិត្យគ្រឿងញៀន និងដោយចង់អោយអង្គការអន្តរជាតិដែលពាក់ព័ន្ធទាំងអស់ ឋិតនៅក្នុងក្របខ័ណ្ឌការងាររបស់អង្គការនោះ ។

ដោយចង់អោយបញ្ចូលអនុសញ្ញាអន្តរជាតិ ដែលអាចទទួលយកបានជាទូទៅមួយ ជំនួសសន្ធិសញ្ញាដែលមានស្តីពីគ្រឿងញៀន ដែលកិរិតនៃថ្នាំញៀនទាំងនោះចំពោះការប្រើប្រាស់ផ្នែកវិទ្យាសាស្ត្រ និងសុខាភិបាល ហើយផ្តល់សំរាប់ការត្រួតពិនិត្យនិងសហប្រតិបត្តិការអន្តរជាតិជាបន្តដើម្បីសំរេចអោយបាននូវកម្មវត្ថុ និងគោលចំណងទាំងនោះ។

តាមរយៈនេះ សំរេចដូចតទៅ :[២]

មាត្រា ១

និយមន័យ

១- និយមន័យនេះត្រូវប្រើនៅក្នុងអនុសញ្ញានេះទាំងមូល លើកលែងតែមានចំណុចចង្អុលបញ្ជាក់ ឬបរិបទតំរូវ :

ក- " គណៈកម្មការ " មានន័យថាគណៈកម្មការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ។

ខ- " កញ្ឆា " មានន័យថា ត្រួយរបស់ដើមកញ្ឆា ដែលមានផ្លែផ្កា (ដោយមិនរាប់បញ្ចូលស្លឹកនិងគ្រាប់ដែលមិននៅជាប់ជាមួយត្រួយនោះឡើយ) ដែលគេមិនទាន់ចំរាញ់យកជ័រចេញ ទោះបីជាមានឈ្មោះអ្វីក៏ដោយ។

គ- " ដើមកញ្ឆា " មានន័យថា ដើមកញ្ឆាប្រភេទណាក៏ដោយ (Genus Cannabis)។

ឃ- "ជ័រកញ្ឆា" មានន័យថា ជ័រដែលផ្តាច់ចេញពីដើមកញ្ឆាទោះបីជានៅឆៅឬបានចំរាញ់ហើយក៏ដោយ ។

ង- "ដើមកូកា" មានន័យថា ដើមប្រភេទណាក៏ដោយនៃអំបូរអេរីត្រូស៊ីឡុន (erythroxylon)។

ច- "ស្លឹកកូកា" មានន័យថា ស្លឹករបស់ដើមកូកាលើកលែងតែស្លឹកដែលគេបានចំរាញ់យកចេញនូវសារធាតុកាល់កាលូអ៊ីត អ៊ីកហ្គូនីនទាំងអស់ កូកាអ៊ីន និងអ៊ីកហ្គូនីនដទៃទៀតចេញ។

ឆ- "គណៈកម្មាការ" មានន័យថា គណៈកម្មការស្តីពីក្រុមប្រឹក្សាគ្រឿងញៀន ។

ជ- "ក្រុមប្រឹក្សា" មានន័យថា ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ ។

ឈ- "ការដាំដុះ" មានន័យថា ការដាំដុះអាភៀន ដើមកូកា ឬ ដើមកញ្ឆា ។

---

[២] កំណត់សំគាល់ដោយលេខាធិការដ្ឋាន : បុព្វកថាចំពោះពិធីសារដែលធ្វើការកែប្រែអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ១៩៦១ មានខ្លឹមសារដូចតទៅ:

" ភាពចាំបាច់ឃើញថាចំពោះពិធីសារបច្ចុប្បន្ន .

" ពិចារណាទៅលើបទបញ្ញត្តិនៃអនុសញ្ញាទោលស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ ធ្វើនៅទីក្រុងញ៉ូយ៉ក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៦១ (ហៅថាអនុសញ្ញាទោល) ។

" ដោយចង់ធ្វើការកែប្រែអនុសញ្ញាទោល ។

" សំរេចដូចតទៅ :

ញ- " ថ្នាំញៀន " មានន័យថា សារធាតុណាក៏ដោយដែលមាននៅក្នុងតារាងមួយ និងតារាងពីរ ទោះបីជាសំយោគ ឬ ធម្មជាតិក៏ដោយ ។

ដ -" មហាសន្និបាត " មានន័យថា មហាសន្និបាតរបស់អង្គការសហប្រជាជាតិ ។

ឋ- " ចរាចរខុសច្បាប់ " មានន័យថា ការដាំ ឬការចរាចរថ្នាំញៀន ដោយផ្ទុយទៅនឹងបទបញ្ញត្តិនៃអនុសញ្ញានេះ ។

ឌ- "អាហរ័ណ " និង "នីហរ័ណ" មានន័យថា ក្នុងន័យលាក់កំបាំងរបស់វាថា ការបញ្ជូនថ្នាំញៀនតាមសេរីរាងកាយពីរដ្ឋមួយទៅរដ្ឋមួយផ្សេងទៀត ពីទឹកដីមួយទៅកាន់ទឹកដីមួយផ្សេងទៀតនៅក្នុងរដ្ឋតែមួយ ។

ឍ- "ការផលិត " មានន័យថា គ្រប់ដំណើរការទាំងអស់ដែលគេអាចទទួលបានថ្នាំញៀនដោយមិនសំដៅតែទៅលើការផលិតប៉ុណ្ណោះទេ ហើយរាប់បញ្ចូលទាំងការចំរាញ់ ទាំងការបំលែងថ្នាំញៀនទាំងនោះឱ្យទៅជាថ្នាំញៀនដទៃទៀតផងដែរ ។

ណ- "អាភៀនឱសថ " មានន័យថា អាភៀនដែលបានផលិតទៅតាមដំណើរការចាំបាច់ ដើម្បីធ្វើវាតំរូវសំរាប់ប្រើប្រាស់ក្នុងវិស័យសុខាភិបាល ។

ត- " អាភៀន " មានន័យថា ទឹកដមរបស់ដើមអាភៀនដែលកក ។

ថ- " ដើមអាភៀន " មានន័យថា ដើមរុក្ខជាតិប្រភេទ ប៉ាប៉ាវើ សំនីហ្វ្រើមអិល (Papaver Sonniferuml)

ទ- " ដើមអាភៀនស្ងួត " មានន័យថា គ្រប់ផ្នែកទាំងអស់ (លើកលែងតែគ្រាប់ចេញ) របស់ដើមអាភៀនក្រោយពេលច្រូតកាត់មក ។

ធ- "ការរៀបចំ " មានន័យថា ការច្របល់ចូលនូវវត្ថុធាតុរឹង ឬ រាវ ដែលមានផ្ទុកថ្នាំញៀន ។

ន- " ការផលិត " មានន័យថា ការបំបែកអាភៀន ស្ពឹកកូកា កញ្ឆា និង ជ័រកញ្ឆាចេញពីដើមវា ដើម្បីទទួលបាននូវវត្ថុធាតុទាំងអស់នេះ ។

ប- "តារាង១" "តារាង២" "តារាង៣" និង "តារាង៤" មានន័យថា បញ្ជីចុះចំនួនថ្នាំញៀនទាក់ទងគ្នា ឬការរៀបចំដែលបានបញ្ចូលជាឧបសម្ព័ន្ធទៅលើអនុសញ្ញានេះ នៅពេលដែលបានធ្វើវិសោធនកម្មម្តង១ ដោយអនុលោមទៅតាមមាត្រា ៣ ។

៨- "អគ្គលេខាធិការ" មានន័យថា អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ ។

៣- "សន្និធិពិសេស" មានន័យថា ចំនួនថ្នាំញៀនដែលបានរក្សាទុកដោយរដ្ឋាភិបាលនៅក្នុងទឹកដី ឬ ប្រទេសរបស់ខ្លួនសំរាប់គោលបំណងពិសេសរបស់រាជរដ្ឋាភិបាលនោះ និង ដើម្បីឆ្លើយតបទៅតាមកាល: ទេស:ពិសេស ហើយការបញ្ជាក់ " គោលបំណងពិសេស " នោះត្រូវបកស្រាយអោយស្របទៅតាមហ្នឹងផងដែរ ។

ក- "សន្និធិ" មានន័យថា ចំនួនថ្នាំញៀនដែលផុកក្នុងប្រទេស ឬ ដែនដីមួយហើយមានចេតនាដើម្បី :

(i)- ប្រើប្រាស់នៅក្នុងប្រទេស ឬ ទឹកដីនោះ សំរាប់បំរើអោយគោលបំណងផ្នែកវិទ្យាសាស្ត្រ និង សុខាភិបាល

(ii)- ប្រើប្រាស់ក្នុងប្រទេស ឬ ទឹកដីនោះ សំរាប់ផលិតថ្នាំញៀន និង សារធាតុផ្សេងៗទៀត ឬ

(iii)- នាំចេញ ប៉ុន្តែមិនរាប់បញ្ចូលចំនួនថ្នាំញៀនដែលទុកនៅក្នុងប្រទេស ឬ ដែនដីនោះឡើយ.

(iv)- តាមរយៈអ្នកលក់រាយ ឬក៏តាមរយៈអ្នកចែកចាយលក់រាយដែលមានអាជ្ញាប័ណ្ណផ្សេងទៀត និង តាមរយៈស្ថាប័ន ឬ ជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការអនុវត្តន៍ មុខងារផ្នែកវិទ្យាសាស្ត្រ ឬ ផ្នែកព្យាបាលដែលមានអាជ្ញាយ៉ាងត្រឹមត្រូវ ឬ

(v)- ដូច "សន្និធិពិសេស"

ម- " ទឹកដី " មានន័យថា ផ្នែកណាមួយនៃរដ្ឋមួយដែលចាត់ទុកថា ជាអង្គភាពដាច់ដោយឡែកមួយ សំរាប់អនុវត្តន៍ប្រព័ន្ធប័ណ្ណនាំចូល ឬ អាជ្ញានាំចេញដែលមានចែងនៅក្នុងមាត្រា ៣១ ។ និយមន័យនេះ មិនត្រូវអនុវត្តន៍ចំពោះពាក្យ "ដែនដី" ដូចដែលបានប្រើនៅក្នុងមាត្រា ៤២ និង ៤៦ ទេ ។

២- សំរាប់គោលបំណងនៃអនុសញ្ញានេះ ថ្នាំញៀនត្រូវចាត់ទុកថា "ប្រើប្រាស់" នៅពេលណាគេផ្តត់ផ្តង់ទៅអោយជនណាម្នាក់ ឬ សហគ្រាសណាមួយ ដើម្បីចែកចាយលក់រាយ សំរាប់ប្រើប្រាស់ផ្នែកសុខាភិបាល ឬ ស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ ហើយត្រូវបកស្រាយអោយត្រឹមត្រូវទៅតាមការប្រើប្រាស់នោះ ។

មាត្រា ២

សារធាតុដែលស្ថិតក្រោមការត្រួតពិនិត្យ

១- ថ្នាំញៀនទាំងអស់ដែលមាននៅក្នុងតារាង I ត្រូវត្រួតពិនិត្យទៅតាមគ្រប់វិធានត្រួតពិនិត្យ ដែលអនុវត្តន៍ចំពោះថ្នាំញៀនទាំងអស់ ដែលចឹតនៅក្រោមអនុសញ្ញានេះ ហើយជាពិសេសចំពោះ

ថ្នាំញៀនទាំងអស់ ដែលរៀបរាប់នៅក្នុងមាត្រា ៤ (គ) ១៩, ២០, ២១, ២៥, ៣០, ៣១, ៣២, ៣៣, ៣៤, និង ៣៧ លើកលែងតែ ដូចជាចំពោះវិធានការត្រួតពិនិត្យ ដែលគេបានកំរិត ចំពោះថ្នាំញៀនដែលបានបញ្ជាក់ ។

២- ថ្នាំញៀនទាំងអស់នៅក្នុងតារាង II ត្រូវត្រួតពិនិត្យតាមវិធានការតែមួយដូចគ្នា នឹងថ្នាំញៀននៅក្នុងតារាង I ដោយលើកលែងតែវិធានការទាំងឡាយដែលមានចែងក្នុងមាត្រា ៣០ នៃកថាខ័ណ្ឌទី ២ និងទី ៥ ក្នុងការលក់រាយ ។

៣- ការរៀបចំផ្សំថ្នាំញៀន ក្រៅពីថ្នាំញៀនទាំងនោះដែលមាននៅក្នុងតារាង III ត្រូវត្រួតពិនិត្យទៅតាមវិធានការតែមួយដូចថ្នាំញៀនដែលពួកគេមាន ប៉ុន្តែការចាំនំស្នាន់ (មាត្រា ១៩) និង ស្ថិតិ (មាត្រា ២០) ដាច់ចេញពីវិធានការពាក់ព័ន្ធថ្នាំញៀនទាំងនេះ នឹងមិនត្រូវតំរូវអោយមាននៅក្នុងករណីរៀបចំផ្សំថ្នាំញៀននោះទេ ហើយមាត្រា ២៩ កថាខ័ណ្ឌ ២ (គ) និង មាត្រា ៣០ កថាខ័ណ្ឌ (ខ) (ii) មិនត្រូវអនុវត្តន៍ឡើយ។

៤- ការរៀបចំនៅក្នុងតារាង III ត្រូវតែត្រួតពិនិត្យទៅតាមវិធានការតែមួយដូចគ្នា នឹង ការរៀបចំថ្នាំញៀននៅក្នុងតារាង II លើកលែងតែមាត្រា ៣១ កថាខ័ណ្ឌទី ១ (ខ) និង ៣ ដល់ ១៥ នោះមិនត្រូវអនុវត្តន៍ឡើយ និងចំពោះ ការទទួលបានរបស់គេ និងការចែកចាយរាយ មាត្រា ៣៤ កថាខណ្ឌ (ខ) មិនត្រូវអនុវត្តឡើយ ហើយបញ្ហានេះ សំរាប់គោលបំណងចាំនំស្នាន (មាត្រា ១៩) និងស្ថិតិ (មាត្រា ២០) ពតិមានដែលតំរូវឱ្យមាន ត្រូវដាក់កំរិតទៅលើបរិមាណថ្នាំញៀនដែលប្រើនៅក្នុងការផលលិត ទៅតាមការរៀបចំផ្សំបែបនោះ ។

៥- ថ្នាំញៀនដែលមាននៅក្នុងតារាង IV ត្រូវបានបញ្ចូលទៅក្នុងតារាង I ផងដែរ ហើយត្រូវតែត្រួតពិនិត្យទៅតាមវិធានការទាំងឡាយដែលអនុវត្តន៍ចំពោះថ្នាំញៀន ដូចមាននៅក្នុងតារាងក្រោយៗ និងលើសពីនេះ ។

ក- ភាគីមួយ ត្រូវអនុម័តទៅលើវិធានការត្រួតពិនិត្យពិសេសទាំងឡាយណាដែលចាំបាច់ ទៅតាមការយល់ឃើញរបស់ខ្លួន ដោយមានការយល់ឃើញដល់គុណភាពថ្នាំញៀនដែលបាត់បង់ដោយរន្ធើរៗនោះ ក៏ត្រូវបានបញ្ចូលផងដែរ ហើយ

ខ- ប្រសិនបើតាមទស្សនៈរបស់ខ្លួន លក្ខខ័ណ្ឌទូទៅនៅក្នុងប្រទេសនោះ ធ្វើអោយរាំងស្ទះដល់មធ្យោបាយការពារសុខុមាលភាព និងសុខភាពសាធារណៈ ភាគីនោះត្រូវហាមឃាត់ដល់ការផលិត ការធ្វើ ការនាំចូល ការនាំចេញ ការធ្វើជំនួញ ការកាន់កាប់ ឬការប្រើប្រាស់ថ្នាំញៀនទាំងនោះ លើកលែងតែចំពោះបរិមាណដែលចាំបាច់ប្រើសំរាប់ការស្រាវជ្រាវវិទ្យាសាស្ត្រ និងសុខាភិបាលតែមួយគត់ ដោយរាប់បញ្ចូលទាំងការសាកល្បងធ្វើការព្យាបាលជាមួយថ្នាំញៀន ដែលឋិតនៅក្រោម ឬត្រូវតែត្រួតពិនិត្យដោយផ្ទាល់ពីភាគីនោះ ។

៦- ក្រៅពីវិធានការត្រួតពិនិត្យដែលអនុវត្តន៍ទៅលើថ្នាំញៀនទាំងអស់នៅក្នុងតារាង I អាស្រ្តែនត្រូវឋិតនៅក្រោមបទបញ្ជត្តិទាំងឡាយនៃមាត្រា ១៩ កថាខណ្ឌ (ច) និងមាត្រា ២១ សូន មាត្រា ២៣ និង មាត្រា ២៤ ស្តីពីកូកា ត្រូវឋិតនៅ ក្រោមបទបញ្ជត្តិនៃមាត្រា ២៦ និង មាត្រា ២៧ ហើយកញ្ឆាឋិតនៅក្រោមបទបញ្ជត្តិ នៃមាត្រា ២៨ ផងដែរ ។

៧- ដើមអាភៀន ដើមកូកា ដើមកញ្ឆា ដើមអាភៀនក្រៀម និង ស្លឹកកញ្ឆា ត្រូវតែត្រួតពិនិត្យទៅតាមវិធានការនីមួយៗដែលបានរៀបរាប់នៅក្នុងមាត្រា មាត្រា ១៩ កថាខណ្ឌ ១ អនុកថាខ័ណ្ឌ (ង) មាត្រា ២០ កថាខណ្ឌទី ១ អនុកថាខណ្ឌ (ឆ) មាត្រា ២១ សូន និង ក្នុងមាត្រា ២២ ដល់ មាត្រា ២៤. មាត្រា ២២ មាត្រា ២៦ និង មាត្រា ២៧. មាត្រា ២២ និង ២៨. មាត្រា ២៥ និងមាត្រា ២៨ ដាច់ៗគ្នា ។

៨- ភាគីទាំងអស់ ត្រូវប្រើប្រាស់កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនអោយអស់ពីកំលាំងកាយចិត្ត ដើម្បីអនុវត្តន៍ចំពោះសារធាតុទាំងឡាយដែលមិនឋិតនៅក្រោមអនុសញ្ញានេះ ប៉ុន្តែគេអាចប្រើប្រាស់ការផលិតគ្រឿងញៀនខុសច្បាប់ ដែលវិធានការនៃការត្រួតពិនិត្យបែបនេះអាចអនុវត្តន៍បាន ។

៩- គេមិនត្រូវតំរូវអោយភាគីទាំងអស់ អនុវត្តន៍នូវបទបញ្ជត្តិនៃអនុសញ្ញានេះ ចំពោះថ្នាំញៀនដែលគេនិយមប្រើប្រាស់ក្នុងឧស្សាហ៍កម្មសំរាប់គោលបំណងក្រៅពីផ្នែកវិទ្យាសាស្ត្រ ឬ សុខាភិបាល ដែលបានចែងថា :

ក- ពួកគេបានាអោយបាន តាមរយៈវិធីសាស្ត្រសមស្របខុសពីធម្មជាតិ ឬតាមរយៈមធ្យោបាយដទៃទៀត ដែលគេប្រើថ្នាំញៀន ដែលមិនអាចនឹងមានការបំពានគ្រឿងញៀន ឬមានឥទ្ធិពលអាក្រក់ (មាត្រា៣នៃកថាខ័ណ្ឌទី៣) ហើយដែលនៅក្នុងការអនុវត្តន៍ គេមិនអាចទាញយកសារធាតុ ដែលមានគ្រោះថ្នាក់ទាំងនោះមកវិញបានឡើយ ។

ខ- ពួកគេបញ្ចូលទៅក្នុងពត៌មានស្ថិតិ (មាត្រា ២០) ដែលបានចែង ដោយផ្តល់អោយពួកគេនូវ បរិមាណថ្នាំញៀននីមួយៗដែលបានប្រើប្រាស់ ។

មាត្រា ៣

ការផ្ទាស់ប្តូរវិសាលភាពនៃការត្រួតពិនិត្យ

១- កន្លែងដែលភាគីមួយ ឬអង្គការសុខភាពពិភពលោកមានពត៌មាន ដែលតាមទស្សនៈផ្ទាល់របស់ខ្លួន អាចតំរូវឱ្យមានការធ្វើវិសោធនកម្មលើតារាងណាមួយ ខ្លួនត្រូវប្រកាសជូនដំណឹងដល់អគ្គលេខាធិការ ហើយផ្តល់នូវពត៌មានដែលឆ្លើយតបនឹងការជូនដំណឹងនោះ ។

២- អគ្គលេខាធិការត្រូវបញ្ជូនការជូនដំណឹងបែបហ្នឹង ហើយនិងពត៌មានដទៃទៀត ដែលគិតថាទាក់ទងនឹងគ្នាអោយទៅគ្រប់ភាគីទៅគណៈកម្មការ និងទីកន្លែងដែលភាគីមួយធ្វើការជូនដំណឹងទៅអោយ អង្គការសុខភាពពិភពលោក ។

៣- កន្លែងដែលការជូនដំណឹងមួយ ជាប់ទាក់ទិនទៅនឹងសារធាតុមួយ មិនទាន់មាននៅឡើយ នៅក្នុង តារាង I ឬនៅក្នុងតារាង II ។

(i) ភាគីទាំងអស់ ត្រូវពិនិត្យពិចៃមើលលទ្ធភាពនៃការអនុវត្តន៍បណ្តោះអាសន្ន ចំពោះសារធាតុ នេះត្រូវបិទានការត្រួតពិនិត្យទាំងអស់ដែលអនុវត្តន៍ទៅលើថ្នាំញៀនក្នុងតារាង I ដោយមាន ពត៌មានដែលគេរកបាន ។

(ii) ដោយរង់ចាំសេចក្តីសំរេចរបស់ខ្លួន ដូចដែលបានចែងនៅក្នុងអនុកថាខ័ណ្ឌ (iii) នៃកថាខ័ណ្ឌ នេះ គណៈកម្មការអាចសំរេចអោយភាគីទាំងឡាយ អនុវត្តន៍ចំពោះសារធាតុនោះជាបណ្តោះ អាសន្ននូវវិធានការត្រួតពិនិត្យការអនុវត្តន៍គ្រឿងញៀននៅក្នុងតារាង(I) ។ ភាគីទាំងឡាយ ត្រូវតែអនុវត្តន៍នូវវិធានការមួយចំនួនជាបណ្តោះអាសន្នចំពោះសារធាតុដែលមានបញ្ហា ។

(iii) ប្រសិនបើអង្គការសុខភាពពិភពលោកដឹងថា សារធាតុរវាងមានការប្រើប្រាស់ខុស ហើយ ផ្តល់ផលអាក្រក់ស្រដៀងគ្នានឹងថ្នាំញៀនក្នុងតារាង I ឬក្នុងតារាង II ឬក៏ប្រែទៅជាថ្នាំ ញៀនមួយវិញនោះ វាត្រូវប្រាប់អំពីការរកឃើញនោះដល់គណៈកម្មការដែលអាចសំរេចថា សារធាតុនោះត្រូវបញ្ចូលបន្ថែមទៅក្នុងតារាង I ឬក្នុងតារាង II ដោយអនុលោមទៅតាម អនុសាសន៍របស់អង្គការសុខភាពពិភពលោក ។

៤- ប្រសិនបើអង្គការសុខភាពពិភពលោក រកឃើញថា មានការរៀបចំមួយ ដោយសារតែសារធាតុដែលទុកនោះ មិនអាចនឹងមានការប្រើប្រាស់ខុស ហើយមិនបង្កើតអោយមានឥទ្ធិពលអាក្រក់ (កថាខ័ណ្ឌ ទី ៣) ហើយដឹងថា ថ្នាំញៀន ដែលមាននៅក្នុងនោះ មិនអាចប៉ះលែងបាននោះ គណៈកម្មការ អាចបញ្ចូលការរៀបចំនោះបន្ថែមទៅក្នុងតារាង III ដោយអនុលោមទៅតាមអនុសាសន៍ របស់អង្គការសុខភាពពិភពលោក។

៥- ប្រសិនបើអង្គការសុខភាពពិភពលោក ដឹងថាថ្នាំញៀនមួយក្នុងតារាង I អាចនឹងមានការប្រើប្រាស់ខុស ជាពិសេសនឹងអាចបង្កើតអោយមានឥទ្ធិពលអាក្រក់ (កថាខ័ណ្ឌ ទី ៣) ហើយដឹងថាផលអាក្រក់បែបនោះ មិនអាចកើតចេញមកពីសារៈប្រយោជន៍ព្យាបាលរោគត្រឹមត្រូវ ដែលគ្មានក្នុងសារធាតុទាំងនោះ ក្រៅពីថ្នាំញៀនក្នុងតារាង IV នោះគណៈកម្មការ អាចដាក់ថ្នាំញៀននោះ ចូលក្នុងតារាង IV។

៦- ទីកន្លែងណាមួយមានសេចក្តីប្រកាសជូនដំណឹងទាក់ទងនឹងថ្នាំញៀនមួយដែលមានជាស្រេច ក្នុងតារាង I ឬតារាង II ឬទាក់ទងនឹងការរៀបចំមួយក្នុងតារាង III ដាច់ចេញពីវិធានការដែលបានផ្តល់អោយដូចមានចែងនៅក្នុងកថាខ័ណ្ឌទី ៥ នោះ គណៈកម្មការ អាចធ្វើវិសោធនកម្មតារាងណាមួយ ដោយអនុលោមទៅតាមអនុសាសន៍របស់អង្គការសុខភាពពិភពលោកដោយ:

ក- ការផ្ទេរថ្នាំញៀនមួយពីតារាង I ទៅក្នុងតារាង II ឬពីតារាង II មកចូលតារាង I វិញ ឬ

ខ- លុបចោលថ្នាំញៀនមួយ ឬការរៀបចំមួយចេញពីតារាងមួយ នៅពេលមានករណីបែបនេះ។

៧- សេចក្តីសំរេចណាមួយរបស់គណៈកម្មការដែលបានធ្វើឡើងស្របទៅនឹងមាត្រានេះ អគ្គលេខាធិការត្រូវប្រកាសជូនដំណឹងដល់សមាជិករបស់អង្គការសហប្រជាជាតិ ភាគីរដ្ឋដែលមិនមែនជាសមាជិក នៃអនុសញ្ញានេះអង្គការសុខភាពពិភពលោក និងដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ។ សេចក្តីសំរេចបែបនេះត្រូវចូលជាធរមានចំពោះភាគីនីមួយៗ ចាប់ពីថ្ងៃទទួលដំណឹងរបស់ខ្លួន ហើយភាគីទាំងអស់នៅពេលនោះត្រូវចាត់វិធានការបែបហ្នឹង នៅពេលណាគេតំរូវនៅក្នុងអនុសញ្ញានេះ ។

៨- ក- សេចក្តីសំរេចធ្វើវិសោធន៍កម្មទៅលើតារាងណាមួយរបស់គណៈកម្មការ ត្រូវតែពិនិត្យដោយហ្មត់ចត់ឡើងវិញដោយក្រុមប្រឹក្សាទៅលើសំណើរបស់ភាគីណាមួយ ដែលបានធ្វើប្រតិវេទក្នុងរយៈពេល ៩០ថ្ងៃចាប់ពីថ្ងៃទទួលសេចក្តីប្រកាសជូនដំណឹង ស្តីពីសេចក្តីសំរេចនោះ ។ សំណើអោយពិនិត្យ

ឡើងវិញ ត្រូវបញ្ជូនទៅអោយអគ្គលេខាធិការព្រមគ្នាជាមួយឯកសារមានពាក់ព័ន្ធ ដោយសំអាងទៅលើសំណើសុំអោយត្រួតពិនិត្យមើលឡើងវិញ ។

ខ- អគ្គលេខាធិការត្រូវបញ្ជូនច្បាប់ចំតចម្លង នៃសំណើសុំត្រួតពិនិត្យឡើងវិញ និងឯកសារដែលពាក់ព័ន្ធនោះ ទៅអោយគណៈកម្មការអង្គការសុខភាពពិភពលោក និងទៅឱ្យភាគីទាំងអស់ ដោយអញ្ជើញពួកគេអោយដាក់ជូននូវសេចក្តីអធិប្បាយ ក្នុងរយៈពេល៩០ថ្ងៃ ។ សេចក្តីអធិប្បាយទាំងអស់ដែលបានទទួល ត្រូវដាក់ជូនទៅក្រុមប្រឹក្សាដើម្បីពិនិត្យ ។

គ- ក្រុមប្រឹក្សាអាចអះអាងបញ្ជាក់កែតម្រូវ ឬប្តូរសេចក្តីសំរេចរបស់គណៈកម្មការនោះបញ្ជូនសេចក្តីសំរេចរបស់ក្រុមប្រឹក្សា តជាសេចក្តីសំរេចចុងក្រោយ។ សេចក្តីប្រកាសជូនដំណឹងរបស់ក្រុមប្រឹក្សាត្រូវបញ្ជូនទៅឱ្យគ្រប់រដ្ឋទាំងអស់ ដែលជាសមាជិករបស់អង្គការសហប្រជាជាតិ ភាគីរដ្ឋដែលមិនមែនជាសមាជិកអនុសញ្ញានេះ គណៈកម្មការអង្គការសុខភាពពិភពលោក និងទៅឱ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ។

ឃ- ក្នុងកំឡុងពេលផ្អាកនៃការត្រួតពិនិត្យមើលឡើងវិញនោះ សេចក្តីសំរេចដើមរបស់គណៈកម្មការត្រូវនៅមានប្រសិទ្ធភាពដដែល ។

៩- ដោយអនុលោមទៅតាមមាត្រានេះ សេចក្តីសំរេចរបស់គណៈកម្មការដែលបានធ្វើឡើង មិនត្រូវមាននីតិវិធីត្រួតពិនិត្យឡើងវិញដែលបានចែងក្នុងមាត្រា ៧ ឡើយ ។

មាត្រា ៤
កាតព្វកិច្ចទូទៅ

១- ភាគីទាំងអស់ ត្រូវចាត់វិធានការតាមផ្លូវច្បាប់ និងរដ្ឋបាលបែបនោះ នៅពេលណាមានការចាំបាច់ :

ក- ដើម្បីផ្តល់ប្រសិទ្ធភាព និងអនុវត្តបទបញ្ជត្តិនៃអនុសញ្ញានេះ នៅក្នុងដែនដីរបស់ខ្លួន,

ខ- ដើម្បីសហប្រតិបត្តិការជាមួយរដ្ឋដទៃទៀតក្នុងការប្រតិបត្តិបទបញ្ជត្តិនៃអនុសញ្ញានេះ ហើយ

គ- ត្រូវតែមានបទបញ្ជត្តិនៃអនុសញ្ញានេះ ដើម្បីការពារទាំងស្រុងចំពោះគោលបំណង ផ្នែកវិទ្យាសាស្ត្រ និងសុខាភិបាល ការផលិត ការធ្វើ ការនាំចេញ ការនាំចូល ការចែកចាយ ការធ្វើជំនួញ ការប្រើប្រាស់ និងការកាន់កាប់ថ្នាំញៀន ។

មាត្រា ៥

អង្គការត្រួតពិនិត្យអន្តរជាតិ

ដោយទទួលស្គាល់នូវសមត្ថកិច្ចរបស់អង្គការសហប្រជាជាតិ ចំពោះការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ភាគីទាំងអស់ ឯកភាពនូវជំនឿទុកចិត្តទៅលើគណៈកម្មការ ស្តីពីគ្រឿងញៀនរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម និងទៅលើគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ព្រមទាំងមុខងារដែលបានប្រគល់ជូនពួកគេរៀងៗខ្លួននៅក្នុងអនុសញ្ញានេះ ។

មាត្រា ៦

ការចំណាយរបស់អង្គការត្រួតពិនិត្យអន្តរជាតិ

ការចំណាយរបស់គណៈកម្មការ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវផ្តល់អោយដោយអង្គការសហប្រជាជាតិ ក្នុងលក្ខណៈបែបនេះ ត្រូវសំរេចដោយមហាសន្និបាត ។ ភាគីទាំងអស់ដែលមិនមែនជាសមាជិករបស់អង្គការសហប្រជាជាតិ ត្រូវរួមវិភាគទានដល់ការចំណាយទាំងនេះនូវចំនួនដែលមហាសន្និបាតយល់ថា សមស្របតាមពេល និងការវាយតំលៃ បន្ទាប់ពីការប្រឹក្សាជាមួយនឹងរដ្ឋាភិបាលរបស់ភាគីទាំងនេះ ។

មាត្រា ៧

ការពិនិត្យឡើងវិញនូវសេចក្តីសំរេច និងអនុសាសន៍របស់គណៈកម្មការ

លើកលែងតែសេចក្តីសំរេចនៅក្នុងមាត្រា ៣ សេចក្តីសំរេច ឬអនុសាសន៍នីមួយ១ដែលបានអនុម័តដោយគណៈកម្មការ ដោយអនុលោមទៅតាមបទបញ្ញត្តិនៃអនុសញ្ញានេះ ត្រូវតែមានការយល់ព្រម ឬការកែប្រែពីក្រុមប្រឹក្សា ឬមហាសន្និបាតតាម វិធីដូចគ្នានឹងសេចក្តីសំរេច ឬអនុសាសន៍របស់គណៈកម្មការដទៃ១ទៀតដែរ ។

មាត្រា ៨

មុខងាររបស់គណៈកម្មការ

គណៈកម្មការ ត្រូវបានផ្តល់អាជ្ញា អោយដើម្បីពិចារណាទៅលើបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងគោលបំណងរបស់អនុសញ្ញានេះ មកពិនិត្យ ហើយជាពិសេស :

ក-ដើម្បីធ្វើវិសោធនកម្មតារាងទាំងឡាយដោយអនុលោមតាមមាត្រា ៣.

ខ-ដើម្បីជារាបប្រាប់ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិអោយផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាណាមួយ ដែលអាចទាក់ទងនឹងមុខងាររបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិនេះ.

គ-ដើម្បីផ្តល់អនុសាសន៍សំរាប់គោលបំណងនៃការអនុវត្តន៍ និងបទបញ្ជាក្តីនៃអនុសញ្ញានេះដោយរាប់បញ្ចូលនូវកម្មវិធីស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រនិងការផ្ទាស់ប្តូរពត៌មាននៃធម្មជាតិផ្នែកវិទ្យាសាស្ត្រ ឬបច្ចេកទេសហើយនិង.

ឃ- ដើម្បីទាក់ទាញអារម្មណ៍របស់ភាគីមិនមែនជារបស់ខ្លួន អោយយកចិត្តទុកដាក់ទៅលើ សេចក្តីសំរេច និងអនុសាសន៍ទាំងឡាយដែលខ្លួនអនុម័តនៅក្នុងអនុសញ្ញានេះ ជាមួយនឹងការយល់ឃើញចំពោះការយកចិត្តទុកដាក់របស់ពួកគេ ដែលចាត់វិធានការឡើងដោយអនុលោមទៅតាមបញ្ហានោះ ។

មាត្រា ៩

សមាសភាព និងមុខងាររបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ

១- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិត្រូវមានសមាជិក ១៣ រូប ដែលបោះឆ្នោតជ្រើសរើសឡើងដោយក្រុមប្រឹក្សា មានដូចតទៅ :

ក- សមាជិក ៣រូប ដែលមានបទពិសោធន៍ខាងវិជ្ជាពេទ្យ ឱសថវិទ្យា ឬលក់ឱសថ ជ្រើសរើសចេញពីបេក្ខជន ៥រូប ដែលអង្គការសុខភាពពិភពលោកជ្រើសរើសអោយឈរឈ្មោះ និង.

ខ- សមាជិក ១០ រូបទៀត ជ្រើសចេញពីបញ្ជីឈ្មោះបេក្ខជនដែលជ្រើសរើសអោយឈរឈ្មោះ ដោយសមាជិកអង្គការសហប្រជាជាតិ និងភាគីដែលមិនមែនជាសមាជិករបស់អង្គការសហប្រជាជាតិ ។

២- តាមរយៈសមត្ថកិច្ច ភាគីមិនលំអៀង និងភាពគ្មានផលប្រយោជន៍របស់ពួកគេ សមាជិកទាំងអស់របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ គឺជាមនុស្សដែលត្រូវអោយរក្សាការសម្ងាត់ទូទៅ ។ ក្នុងអំឡុងរយៈពេលអណត្តិរបស់ខ្លួន ពួកគេមិនត្រូវមានតំណែងណាមួយ ឬចូលរួមក្នុងសកម្មភាពណាមួយដែលអាចនឹងបណ្តាលអោយប៉ះពាល់ដល់ភាពមិនលំអៀងក្នុងការអនុវត្តន៍មុខងាររបស់ខ្លួន។ ក្នុងការប្រឹក្សាជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ក្រុមប្រឹក្សាត្រូវធ្វើការរៀបចំទាំងអស់

ដែលចាំបាច់ដើម្បីធានាដល់ឯករាជ្យភាពរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ក្នុងការអនុវត្តន៍មុខងាររបស់ខ្លួន ។

៣- ដោយគោរពចំពោះគោលការណ៍នៃការតំណាងភូមិសាស្ត្រ ដែលមានសមធម៌ ក្រុមប្រឹក្សា ត្រូវពិនិត្យពិចារណាទៅលើ សារៈសំខាន់នៃការបញ្ចូលទៅក្នុងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ នូវសមាមាត្រដែលមានសមធម៌ ចំពោះមនុស្សដែលមានចំណេះដឹងពិស្ថានភាពគ្រឿងញៀននៅក្នុង ប្រទេសដែលផលិត ធ្វើ និងប្រើប្រាស់ ហើយដែលជាប់ទាក់ទងនឹងបណ្តាប្រទេសទាំងនោះ ។

៤- នៅក្នុងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាល និង ចំពោះអាណត្តិរបស់អនុសញ្ញានេះ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវខិតខំប្រឹងប្រែង ដើម្បីកំណត់ការដាំ ការផលិត ការធ្វើ និងការប្រើប្រាស់នូវគ្រឿងញៀនអោយបានសមល្មមទៅតាមចំនួនដែលត្រូវការ សំរាប់គោលបំណងផ្នែកឱសថសាស្ត្រ និងវិទ្យាសាស្ត្រ ដើម្បីធានានូវលទ្ធភាពរបស់គេ សំរាប់គោលបំណងទាំងនោះ និង ដើម្បីទប់ស្កាត់ការដាំ ការផលិត និងការធ្វើខុសច្បាប់ ព្រមទាំងការចរាចរ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ។

៥- វិធានការទាំងដែលបានធ្វើឡើងដោយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ដែលស្ថិតនៅក្រោមអនុសញ្ញានេះ នឹងស្របទៅតាមគោលបំណងបន្តកិច្ចសហប្រតិបត្តិការរបស់រដ្ឋាភិបាល ជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ និងដើម្បីផ្តល់យន្តការសំរាប់ការបន្តនូវការពិភាក្សារវាងរដ្ឋាភិបាល និង គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ដែលនឹងផ្តល់ជំនួយ និងសំរួលដល់សកម្មភាពថ្នាក់ជាតិដែលមានប្រសិទ្ធភាព ដើម្បីសំរេចនូវគោលបំណងនៃអនុសញ្ញានេះ ។

មាត្រា ១០

រយៈពេលកាន់តំណែង និងសំណង

របស់សមាជិកគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ

១- សមាជិកគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិទាំងអស់ ត្រូវបំរើការរយៈពេល៥ឆ្នាំ ហើយត្រូវមានសិទ្ធិទទួលបានឡើងវិញតាមរយៈការបោះឆ្នោតជ្រើសរើសសារជាថ្មី ។

២- រយៈពេលកាន់តំណែងរបស់សមាជិកនៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិម្នាក់ៗ ត្រូវបញ្ចប់មួយថ្ងៃមុនពេលកិច្ចប្រជុំលើកទី ១ របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ដែលអ្នកថ្មីត្រូវមានសិទ្ធិចូលក្នុងកិច្ចប្រជុំនេះ ។

៣- សមាជិកគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិរូបណាមួយ ដែលមិនបានចូលរួមក្នុងសម័យប្រជុំបីដងជាប់ៗគ្នា ត្រូវចាត់ទុកថាបានលាលែងពីការងារ ។

៤- ដោយផ្អែកលើអនុសាសន៍របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ក្រុមប្រឹក្សា អាចបណ្តេញសមាជិកគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិណាម្នាក់ ដែលមិនបានបំពេញលក្ខខណ្ឌដែលតំរូវអោយសំរាប់សមាជិកភាព ដូចមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រា ៩ ។ អនុសាសន៍នោះនឹងត្រូវធ្វើឡើងដោយសំលេងបោះឆ្នោតជាក់លាក់នៃសមាជិក ៩ រូបរបស់ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ។

៥- នៅពេលកន្លែងទំនេរកើតឡើងក្នុងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ រយៈពេលកាន់តំណែងរបស់សមាជិកម្នាក់ ក្រុមប្រឹក្សាត្រូវបំពេញកន្លែងនោះភ្លាមតាមដែលអាចធ្វើទៅបាន ហើយដោយអនុលោមទៅតាមបទបញ្ជត្តិដែលអនុវត្តន៍តាមមាត្រា៩ ដោយបោះឆ្នោតជ្រើសរើសសមាជិកម្នាក់ផ្សេងទៀត ដើម្បីអោយបំរើការរយៈពេលដែលនៅសល់ ។

៦- សមាជិករបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិទាំងអស់ ត្រូវទទួលសំណងគ្រប់គ្រាន់ដូចដែលបានកំណត់ដោយមហាសន្និបាត ។

មាត្រា ១១

វិធានន៍នីតិវិធីរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ

១- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវបោះឆ្នោតរើសប្រធានផ្ទាល់របស់ខ្លួន និងមន្ត្រីដទៃទៀតនៅពេលណាខ្លួនគិតថា ចាំបាច់ ហើយត្រូវអនុម័តវិធាននីតិវិធីរបស់ខ្លួន ។

២- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវជួបប្រជុំអោយបានញឹកញាប់ទៅតាមការយល់ឃើញរបស់ខ្លួននៅពេលណាចាំបាច់ដើម្បីបំពេញមុខងាររបស់ខ្លួនអោយបានត្រឹមត្រូវ ប៉ុន្តែត្រូវយ៉ាងហោចណាស់ត្រូវធ្វើពីរ សម័យប្រជុំ ក្នុងឆ្នាំប្រតិទិននីមួយៗ ។

៣- កូរ៉ុំ (ចំនួន) ចាំបាច់ក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវមានសមាជិក ៨ រូប ។

មាត្រា ១២
ការគ្រប់គ្រងប្រព័ន្ធតំលៃចាំនំស្មាន

១- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវកំណត់កាលបរិច្ឆេទមួយ ឬច្រើន តាមរយៈនេះ និងបែបបទមួយដែលក្នុងនោះតំលៃចាំនំស្មាន ដូចមានចែងក្នុងមាត្រា ១៩ ត្រូវផ្តល់ និងត្រូវចេញទំរង់បែបបទដូច្នោះ ។

២- ដោយគោរពដែនដី និងប្រទេសទាំងឡាយដែលមិនបានអនុវត្តន៍អនុសញ្ញានេះ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវស្នើដល់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធនូវតំលៃចាំនំស្មាន ដោយអនុលោមទៅតាមបទបញ្ញត្តិនៃអនុសញ្ញានេះ ។

៣- ប្រសិនបើរដ្ឋណាមួយខកខានមិនបានផ្តល់តំលៃចាំនំស្មាន ដោយគោរពដល់ដែនដីរបស់ខ្លួនតាមកាលបរិច្ឆេទដែលបានបញ្ជាក់នោះ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវបង្កើតតំលៃចាំនំស្មានអោយហួសតាមលទ្ធភាពដែលអាចធ្វើទៅបាន។ ក្នុងការបង្កើតតំលៃចាំនំស្មានបែបហ្នឹង អោយដល់ករិតដែលអាចអនុវត្តន៍បាន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវធ្វើដូច្នេះក្នុងកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ ។

៤- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវពិនិត្យមើលតំលៃចាំនំស្មានដោយរាប់បញ្ចូលតំលៃចាំនំស្មានបន្ថែមបង្គ្រប់ ហើយលើកលែងតំរូវការសំរាប់គោលបំណងពិសេសអាចតំរូវអោយមានពតិមានបែបហ្នឹងនៅពេលណាខ្លួនគិតថាចាំបាច់ ដោយគោរពក្នុងនាមជាប្រទេស ឬទឹកដីមួយដែលគេផ្តល់អោយនូវតំលៃចាំនំស្មានមួយ ដើម្បីបំពេញតំលៃចាំនំស្មាននោះ ឬដើម្បីពន្យល់លើសេចក្តីអះអាងណាមួយដែលមាននៅក្នុងនោះ ។

៥- ដោយសារមានការកំណត់នូវការប្រើប្រាស់ និងការចែកចាយគ្រឿងញៀនទៅតាមចំនួនសមស្របដែលតំរូវអោយមានសំរាប់គោលបំណងផ្នែកឱសថសាស្ត្រ និងវិទ្យាសាស្ត្រ និងដើម្បីធានាលទ្ធភាពរបស់គេសំរាប់គោលបំណងទាំងនោះ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវអះអាងបញ្ជាក់លើតំលៃចាំនំស្មានយ៉ាងរួសរាន់ តាមដែលអាចធ្វើទៅបានដោយ បញ្ចូលតំលៃចាំនំស្មានបន្ថែមបង្គ្រប់ ឬអាចធ្វើវិសោធនកម្មលើតំលៃ ចាំនំស្មាននេះ ដោយមានការយល់ព្រមពីរដ្ឋាភិបាលដែលពាក់ព័ន្ធ ។ ក្នុងករណីមិនមានការព្រមព្រៀង រវាងរដ្ឋាភិបាល និង គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ

ចំណុចចុងក្រោយ នឹងមានសិទ្ធិបង្កើត ទាក់ទង និងចេញផ្សាយនូវតំលៃប៉ាន់ស្មានរបស់ខ្លួនផ្ទាល់ រួមបញ្ចូលទាំងតំលៃប៉ាន់ស្មានបន្ថែម ។

៦- បន្ថែមលើរបាយការណ៍ដូចមានចែងក្នុងមាត្រា ១៥ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវបញ្ចេញពតិមាន អំពីការប៉ាន់ប្រមាណទាំងនោះតាមយោបល់របស់ខ្លួន និង សំរបសំរួលការអនុវត្តន៍អនុសញ្ញានេះ នៅពេលដែលខ្លួននឹងកំណត់ ប៉ុន្តែយ៉ាងហោចណាស់មួយឆ្នាំម្តង ។

មាត្រា ១៣
ការគ្រប់គ្រងប្រពន្ធ័ស្ថិតិបញ្ជូនត្រឡប់

១. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវកំណត់ពី វិធីសាស្ត្រ និងទំរង់បែបបទដែលក្នុងនោះការបញ្ជូនស្ថិតិត្រឡប់នឹងត្រូវផ្តល់ជូនដូចមានចែងក្នុងមាត្រា ២០ និងត្រូវរៀបរាប់អំពី ទំរង់បែបបទទាំងនោះ ។

២. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវពិនិត្យការបញ្ជូនត្រឡប់ជាមួយនឹងទស្សនៈនៃការកំណត់ ថាតើភាគីមួយ ឬរដ្ឋផ្សេងទៀតណាមួយ បានគោរពតាមបទបញ្ជត្តិនៃអនុសញ្ញានេះដែរ ឬទេ ។

៣. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ អាចត្រូវការពតិមាននោះបន្ថែមប្រសិនបើខ្លួនយល់ឃើញថាជាការចាំបាច់ក្នុងការបញ្ជាប់ ឬដើម្បីបកស្រាយពតិមានដែលមាននៅក្នុងស្ថិតិបញ្ជូនត្រឡប់ទាំងនោះ ។

៤. មិនត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ក្នុងការចោទសួរ ឬបញ្ចេញគំនិតណាមួយលើពតិមានរបស់ស្ថិតិទាក់ទងនឹងគ្រឿងញៀន ដែលតម្រូវចំពោះគោលបំណងពិសេសទាំងនេះ ។

មាត្រា ១៤
វិធានការរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ដើម្បីធានាចំពោះការអនុវត្តន៍បទបញ្ជត្តិនៃអនុសញ្ញា

១. (ក)ដោយផ្អែកលើការត្រួតពិនិត្យរបស់ខ្លួនលើពតិមាន ដែលរដ្ឋាភិបាលបានដាក់ជូនទៅគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ស្របតាមបទបញ្ជត្តិនៃអនុសញ្ញានេះ ឬតាមពតិមានដែល

អង្គការសហប្រជាជាតិ ឬភ្នាក់ងារពិសេស ឬ ដោយចែងថា ពតិមានត្រូវបានអនុម័តដោយ គណៈកម្មាការស្តីពីអនុសាសន៍របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ តាមរយៈ អង្គការអន្តរដ្ឋាភិបាលផ្សេង១ទៀត ឬអង្គការក្រៅរដ្ឋាភិបាលដែលមានសមត្ថកិច្ចផ្តាល់នៅក្នុង បញ្ហានោះ ហើយដែលស្ថិតនៅក្នុងឋានៈពិគ្រោះយោបល់ជាមួយនិងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ស្របតាមមាត្រា ៧១ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ឬ ទទួលនូវឋានៈប្រហាក់ប្រហែលគ្នា មួយដោយកិច្ចព្រមព្រៀងពិសេសជាមួយក្រុមប្រឹក្សា គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន អន្តរជាតិ មានហេតុផលមិនល់អៀងចំពោះការជឿទុកចិត្តថា គោលបំណងនៃអនុសញ្ញានេះ កំពុង ត្រូវបានធ្វើអោយមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ដោយសារហេតុផលនៃការបរាជ័យរបស់ភាគីណាមួយ ប្រទេស ឬទឹកដីណាមួយ ដើម្បីអនុវត្តន៍បទបញ្ញត្តិនៃអនុសញ្ញានេះ គណៈកម្មាធិការត្រួតពិនិត្យ គ្រឿងញៀនអន្តរជាតិ នឹងមានសិទ្ធិស្នើឡើងទៅរដ្ឋាភិបាលដែលពាក់ព័ន្ធអោយមានការបើកចំហនូវ ការពិគ្រោះយោបល់ ឬស្នើអោយពួកគេផ្តល់ការពន្យល់ ។ ដោយគ្មានការខកខានណាមួយនៅក្នុង ការអនុវត្តន៍បទប្បញ្ញត្តិនៃអនុសញ្ញា ប្រសិនបើភាគីមួយ ប្រទេសមួយ ឬទឹកដីបានក្លាយទៅជា សមាជិកនៃអនុសញ្ញា ឬប្រសិនបើមានកស្តុតាងនៃការគ្រោះថ្នាក់ធ្ងន់ធ្ងរ ដែលវាអាចកើតមានឡើង ឬប្រសិនបើមានកស្តុតាងនៃការគ្រោះថ្នាក់ធ្ងន់ធ្ងរ មជ្ឈមណ្ឌលសំខាន់នៃការដាំ ការផលិត ឬការធ្វើ ឬការចរាចរ ឬការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរ ជាតិ មានសិទ្ធិស្នើសុំទៅរដ្ឋាភិបាលដែលពាក់ព័ន្ធអោយបើកចំហនូវការពិគ្រោះយោបល់ ។ ដោយ កំណត់ចំពោះសិទ្ធិរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ក្នុងការបញ្ជាក់ជូនដល់ ភាគីនានា ក្រុមប្រឹក្សា និងគណៈកម្មការទទួលបន្ទុកលើបញ្ហាដូចដែលបានលើកឡើងក្នុងអនុកថា ខណ្ឌ (ឃ) ខាងក្រោម គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវចាត់ទុកថាជាការ សំងាត់ចំពោះសំណើ សំរាប់ពតិមាន ឬការបកស្រាយណាមួយរបស់រដ្ឋាភិបាល ឬសំណើមួយ សំរាប់ ការពិគ្រោះយោបល់ និងការពិគ្រោះយោបល់ផ្សេង១ទៀតដែលធ្វើឡើងជាមួយរដ្ឋាភិបាល ស្រប តាមអនុកថាខ័ណ្ឌនេះ ។

(ខ) បន្ទាប់ពីការចាត់វិធានការតាមអនុកថាខ័ណ្ឌ(ក)ខាងលើ ប្រសិនបើឯកភាពថា វាជាការចាំបាច់ ក្នុងការធ្វើដូច្នោះ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ អាចអំពាវនាវដល់រដ្ឋាភិបាល ដែលពាក់ពន្ធ័ អោយអនុម័តវិធានការឧបាស្រ័យ ដូចដែលស្ថិតនៅក្រោមកាលៈទេសៈចាំបាច់ក្នុងការ អនុវត្តន៍បទបញ្ញត្តិនៃអនុសញ្ញានេះ ។

(គ) ប្រសិនបើគេគិតថា សកម្មភាពនោះចាំបាច់សំរាប់គោលបំណងនៃការវាយតំលៃបញ្ហា ដោយអនុលោមទៅតាមអនុកថាខណ្ឌ (ក) នៃកថាខណ្ឌនេះ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ អាចស្នើសុំទៅរដ្ឋាភិបាលដែលពាក់ព័ន្ធថា ការសិក្សាបញ្ហាមួយត្រូវបានអនុវត្តនៅក្នុងទឹកដីរបស់ខ្លួន តាមរយៈមធ្យោបាយនានាដូចដែលរដ្ឋាភិបាលចាត់ទុកថាសមស្រប ។ ប្រសិនបើរដ្ឋាភិបាលដែលពាក់ព័ន្ធសំរេច ដើម្បីទទួលរ៉ាប់រងការសិក្សានេះ គេអាចស្នើសុំទៅគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ដើម្បីធ្វើអោយមានជំនាញការ និងសេវាកម្មរបស់មុគ្គលម្នាក់ឬច្រើននាក់ ជាមួយនិងសមត្ថភាពដែលតំរូវអោយមាន ដើម្បីជួយមន្ត្រីរដ្ឋាភិបាលក្នុងការសិក្សាសំណើ ។ បុគ្គលម្នាក់ ឬច្រើននាក់ដែលគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ចង់ធ្វើអោយមានលទ្ធភាព ត្រូវតែមានការយល់ព្រមពីរដ្ឋាភិបាល ។ គំរូនៃការសិក្សានេះ និងពេលវេលាកំណត់ ដែលក្នុងនោះ ការសិក្សាដែលត្រូវបានបញ្ចប់ នឹងត្រូវបានកំណត់ដោយការពិគ្រោះយោបល់រវាងរដ្ឋាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ។ រដ្ឋាភិបាល ត្រូវទំនាក់ទំនងទៅកាន់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិអំពីលទ្ធផលនៃការសិក្សា និងត្រូវចង្អុលបង្ហាញនូវវិធានការសំខាន់ៗដែលគេចាត់ទុកថាមានការចាំបាច់ដើម្បីដោះស្រាយ ។

(ង) ប្រសិនបើ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ រកឃើញថា រដ្ឋាភិបាលដែលពាក់ព័ន្ធមានការខកខានមិនបានផ្តល់ការពន្យល់អោយពេលចិត្ត នៅពេលដែលមានការអំពាវនាវស្រមទៅតាមអនុកថាខណ្ឌ (ក) ខាងលើ ឬមានការខកខានមិនបានអនុម័តវិធានការណ៍ដោះស្រាយណាមួយដែលគេអាចអំពាវនាវអោយចាត់វិធានការណ៍ស្របតាមអនុកថាខណ្ឌ (ខ) ខាងលើ ឬ នោះមានស្ថានភាពធ្ងន់ធ្ងរមួយដែលចាំបាច់ត្រូវមានសកម្មភាពសហប្រតិបត្តិការថ្នាក់តំរិតអន្តរជាតិជាមួយនិងទស្សនៈមួយដើម្បីដោះស្រាយ គេអាចអំពាវនាវអោយមានការយកចិត្តទុកដាក់របស់ភាគីក្រុមប្រឹក្សា និងគណៈកម្មាការចំពោះបញ្ហានេះ ។ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិត្រូវធ្វើដូច្នោះ ប្រសិនបើគោលបំណងនៃអនុសញ្ញានេះ កំពុងត្រូវបានធ្វើអោយមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ និង មិនអាចមានលទ្ធភាព ដើម្បីដោះស្រាយនូវបញ្ហានេះដោយពេញចិត្ត តាមមធ្យោបាយផ្សេងៗទៀត ។ វានឹងធ្វើដូច្នោះផងដែរ ប្រសិនបើគេឃើញថា មានស្ថានភាពធ្ងន់ធ្ងរដែលចាំបាច់ឱ្យមានសកម្មភាពសហប្រតិបត្តិការកំរិតអន្តរជាតិ ជាមួយនិងទស្សនៈមួយដើម្បីដោះស្រាយវា និងដែលនាំអោយមានស្ថានភាពទាំងនោះ ទៅដល់ការកំណត់សំគាល់របស់ភាគីទាំងអស់ ក្រុមប្រឹក្សា និងគណៈកម្មាការ ដែលមានវិធីសាស្ត្រសមស្របបំផុតនៃការសំរបសំរួលនូវសកម្មភាពសហប្រតិបត្តិការ

បន្ទាប់ពីការពិចារណាទៅលើរបាយការណ៍ របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ និងរបស់គណៈកម្មាការ ប្រសិនបើអាចមានលទ្ធភាពទៅលើបញ្ហា ក្រុមប្រឹក្សា អាចធ្វើអោយ មហាសន្និបាតមានការកត់សំគាល់ទៅលើបញ្ហានេះ ។

២. នៅពេលស្នើអោយមានការយកចិត្តទុកដាក់របស់ភាគីនានា ក្រុមប្រឹក្សា និង គណៈកម្មការដែលទទួលបន្ទុកលើបញ្ហានេះ ស្របតាមកថាខ័ណ្ឌ ១ (ឃ) ខាងលើ ប្រសិនបើខ្លួនយល់ថា ទង្វើបែបនេះជាការចាំបាច់ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ អាចផ្តល់អនុសាសន៍ដល់ភាគី ដោយអោយពួកគេបញ្ឈប់ការនាំចូលគ្រឿងញៀន ការនាំចេញគ្រឿងញៀន ឬទង្វើទាំងពីរ មកពី ឬ សំដៅទៅប្រទេស ឬដែនដីពាក់ពន្ធ័ ទោះបីក្នុងពេលវេលាមួយកំណត់ ឬរហូតដល់គណៈកម្មាធិការ ត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិត្រូវបានឯកភាពលើស្ថានភាពក្នុងប្រទេស ឬដែនដីនោះ ។ រដ្ឋពាក់ពន្ធ័ អាចលើកយកបញ្ហានេះដាក់ចំពោះមុខក្រុមប្រឹក្សា ។

៣. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវមានសិទ្ធិបោះពុម្ពរបាយការណ៍ លើបញ្ហាណាមួយដែលបានដោះស្រាយ ដោយអនុលោមទៅតាមបទបញ្ញត្តិនៃមាត្រានេះ ហើយបញ្ជូនរបាយការណ៍នេះទៅអោយក្រុមប្រឹក្សាដែលត្រូវបញ្ជូនបន្តទៅអោយភាគីនានា ។ប្រសិនបើគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ បោះពុម្ពផ្សាយក្នុងរបាយការណ៍នេះនូវសេចក្តីសំរេច ដែលបានធ្វើឡើងស្របតាមមាត្រានេះ ឬពត៌មានណាមួយដែលពាក់ពន្ធ័នឹងរបាយការណ៍នេះ ខ្លួនក៏ត្រូវបោះពុម្ពផ្សាយនូវទស្សនៈរបស់រដ្ឋាភិបាលដែលពាក់ពន្ធ័ផងដែរ ប្រសិនបើមានការស្នើពីរដ្ឋាភិបាលទាំងនោះនៅពេលក្រោយ ។

៤. ប្រសិនបើក្នុងករណីណាមួយ ដែលសេចក្តីសំរេចមួយរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិដែលបានបោះពុម្ពផ្សាយស្របតាមមាត្រានេះមិនមានការឯកភាពជាឯកឆន្ទទេនោះទស្សនៈរបស់មតិភាគតិច ត្រូវបានលើកមកបញ្ជាក់ ។

៥. រដ្ឋណាមួយ ដែលត្រូវបានអញ្ជើញអោយចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិដែលសំណួរមួយមានការចាប់អារម្មណ៍ដោយផ្ទាល់ ត្រូវបានពិចារណាតាមមាត្រានេះ ។

៦. សេចក្តីសំរេចរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិតាមមាត្រានេះ ត្រូវធ្វើឡើងដោយមតិភាគច្រើន ស្មើនឹងពីរភាគបីនៃចំនួនគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ទាំងអស់ ។

មាត្រា ១៤ ស្តួន

ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ

ក្នុងករណីដែលគេចាត់ទុកថាសមស្រប និងក្នុងលក្ខខណ្ឌ ឬ ជាជំរើសផ្សេង។ទៀត ដើម្បីចាត់វិធានការណ៍ដូចមានចែងក្នុងមាត្រា ១៤ កថាខណ្ឌទី ១ និងទី ២ ជាមួយនិងការយល់ព្រមរបស់រដ្ឋាភិបាលដែលពាក់ព័ន្ធ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ អាចផ្តល់អនុសាសន៍ទៅដល់អង្គការសហប្រជាជាតិដែលមានសមត្ថកិច្ច និងទៅដល់ទីភ្នាក់ងារជំនាញដែលជាជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ឬទាំងពីរ ត្រូវបានផ្តល់ទៅដល់រដ្ឋាភិបាលក្នុងការគាំទ្រនូវកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីអនុវត្តន៍កាតព្វកិច្ចរបស់ខ្លួនស្របតាមអនុសញ្ញានេះ រួមបញ្ចូលទាំងការបង្កើតឡើងទាំងអស់នោះ ឬយោងទៅតាមមាត្រា ២ មាត្រា ៣៥ មាត្រា ៣៨ និងមាត្រា ៣៨ ស្តួន ។

មាត្រា ១៥

របាយការណ៍របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ

១. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំលើការងាររបស់ខ្លួន និងរបាយការណ៍បន្ថែមនានា តាមដែលខ្លួនយល់ថាចាំបាច់ដែលត្រូវមាន ព្រមទាំងការវិភាគលើការប៉ាន់ប្រមាណ និងពត៌មានស្ថិតិតាមសិទ្ធិរបស់ខ្លួន និងក្នុងករណីសមស្របប្រវត្តិនៃការពន្យល់បកស្រាយប្រសិនបើមាន ដែលផ្តល់ដោយ ឬតំរូវអោយមានរបស់រដ្ឋាភិបាល រួមជាមួយនឹងការអង្កេតពិនិត្យនានា និងអនុសាសន៍ដែលគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិចង់ធ្វើ ។ របាយការណ៍ទាំងនេះ ត្រូវដាក់ជូនក្រុមប្រឹក្សាតាមរយៈគណកម្មការដែលអាចផ្តល់យោបល់ផ្សេង។ តាមដែលខ្លួនឃើញថាសមស្រប ។

២. របាយការណ៍ត្រូវបញ្ជូនទៅអោយភាគីនិងបន្ទាប់មកត្រូវបានផ្សព្វផ្សាយដោយអគ្គលេខាធិការ ។ ភាគីត្រូវអនុញ្ញាតអោយធ្វើការផ្សព្វផ្សាយ ចែងចែកដោយមិនមានការហាមប្រាមអ្វីទាំងអស់ ។

មាត្រា ១៦
លេខាធិការដ្ឋាន

សេវាកម្មរបស់លេខាធិការដ្ឋាននៃគណៈកម្មការ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវបានផ្តល់អោយដោយអគ្គលេខាធិការ ។ ជាទូទៅ លេខាធិការរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ត្រូវតែងតាំងដោយអគ្គលេខាធិការ ដោយមានការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ។

មាត្រា ១៧
រដ្ឋបាលពិសេស

ភាគីត្រូវរក្សារដ្ឋបាលពិសេសមួយដើម្បីគោលបំណងនៃការអនុវត្តន៍បទបញ្ញត្តិនៃអនុសញ្ញានេះ ។

មាត្រា ១៨
ពត៌មានដែលភាគីត្រូវផ្តល់ជូនទៅអគ្គលេខាធិការ

១. ភាគីត្រូវផ្តល់ជូនទៅអគ្គលេខាធិការនូវពត៌មានទាំងនោះ ដូចដែលគណៈកម្មការអាចស្នើ ដោយសារការចាំបាច់ក្នុងការអនុវត្តន៍តួនាទីរបស់ខ្លួន និងជាពិសេស:

(ក) របាយការណ៍ប្រចាំឆ្នាំ ស្តីអំពី ដំណើរការរបស់អនុសញ្ញានៅក្នុងដែនដីនីមួយៗរបស់ពួកគេ

(ខ) ឯកសារច្បាប់ និងបទបញ្ជាទាំងអស់ ចាប់ពីពេលនេះតទៅ ដែលបានប្រកាសអោយប្រើក្នុងគោលបំណងដើម្បីអោយអនុសញ្ញានេះមានប្រសិទ្ធភាព

(គ) ករណីពិសេសៗទាំងនេះតម្រូវអោយគណៈកម្មការ កំណត់ករណីដែលពាក់ពន្ធ័នឹងចរាចរខុសច្បាប់ ដោយរួមបញ្ចូលទាំងលក្ខណៈពិសេសលើករណីនីមួយៗនៃចរាចរខុសច្បាប់ ដែលបានរកឃើញថាអាចមានសារៈសំខាន់ ដោយសារមានពន្ធីលើប្រភពរបស់គ្រឿងញៀនដែលយកមកធ្វើចរាចរខុសច្បាប់ ឬដោយសារបរិមាណដែលពាក់ពន្ធ័ ឬវិធីសាស្ត្រដែលអ្នកចរាចរខុសច្បាប់ប្រើប្រាស់ និង.

(ឃ) ឈ្មោះ ន័ង អាសយដ្ឋានរបស់អាជ្ញាធររដ្ឋាភិបាល ដែលបានទទួលសិទ្ធិអំណាចក្នុងការចេញលិខិតបញ្ជាក់ ឬការអនុញ្ញាតសំរាប់ការនាំចេញ និងការនាំចូល ។

២. ភាគីត្រូវផ្តល់ពត៌មានដូចមានយោងក្នុងកថាខ័ណ្ឌខាងដើម តាមវិធី និងកាលបរិច្ឆេទ ព្រមទាំងប្រើប្រាស់ទំរង់បែបបទនោះ ដូចដែលគណៈកម្មការអាចស្នើ ។

មាត្រា ១៩
ការចាំន់ប្រមាណគម្រូវការថ្នាំ

១. ភាគីត្រូវផ្តល់ជូនគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ក្នុងមួយឆ្នាំៗ នូវដែនដីនីមួយៗ របស់ខ្លួនតាមវិធី និងទំរង់បែបបទ ដែលបានកំណត់ដោយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ការចាំន់ប្រមាណលើបែបបទដែលខ្លួនបានផ្តល់ជូន មានលក្ខណៈដូចខាងក្រោម :

(ក) បរិមាណថ្នាំដែលត្រូវប្រើប្រាស់សំរាប់គោលបំណងផ្នែកវេជ្ជសាស្ត្រ និង វិទ្យាសាស្ត្រ ។

(ខ) បរិមាណថ្នាំដែលត្រូវប្រើប្រាស់សំរាប់ការផលិតឱសថដទៃទៀត សំរាប់ការរៀបចំក្នុងតារាង III និងសារធាតុដែលមិនមានចែងក្នុងអនុសញ្ញានេះ ។

(គ) ការស្តុកទុកឱសថ ត្រូវបានធ្វើឡើងនៅថ្ងៃ ៣១ ខែ ធ្នូ នៃឆ្នាំ ដើម្បីធ្វើការចាំន់ប្រមាណនូវអ្វីដែលពាក់ព័ន្ធ

(ឃ) បរិមាណឱសថដែលចាំបាច់សំរាប់បន្ថែមលើស្តុកពិសេសៗ ។

(ង) តំបន់ (តិតជាហិកតា) និង ទីតាំងភូមិសាស្ត្រដីដែលត្រូវបានប្រើប្រាស់សំរាប់ដាំអាភៀន ។

(ច) ចាំន់ប្រមាណ បរិមាណអាភៀនដែលត្រូវផលិត ។

(ឆ) ចំនួននៃការបង្កើតឧស្សាហកម្មដែលនឹងផលិតគ្រឿងញៀនសំយោគ និង

(ជ) បរិមាណនៃគ្រឿងញៀនសំយោគ ដែលត្រូវបានផលិតដោយឧស្សាហកម្មនីមួយៗដែលបង្កើតឡើងស្របតាមអនុកថាខណ្ឌពីមុនៗមក ។

២. (ក) ចំពោះការកាត់បន្ថយដោយយោងតាមកថាខ័ណ្ឌ ៣ នៃមាត្រា ២១ ការចាំន់ប្រមាណសរុបលើដែនដីនីមួយៗ និងគ្រឿងញៀននីមួយៗ លើកលែងតែ អាភៀន និងគ្រឿងញៀនសំយោគ ត្រូវមានបរិមាណសរុបដូចដែលបានបញ្ជាក់ក្នុងអនុកថាខ័ណ្ឌ (ក) (ខ) និង (ឃ) កថាខ័ណ្ឌ ១ នៃមាត្រានេះ ជាមួយនឹងតម្រូវការមួយចំនួនក្នុងចំណោមនៃការស្តុកទុកជាក់ស្តែងដែលមានក្នុងដៃនៅថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំ មុនកើនដល់ករិតដែលបានចាំន់ប្រមាណដូច មានចែងក្នុង អនុកថាខ័ណ្ឌ (គ) នៃកថាខ័ណ្ឌ ១ ។

(ខ) ចំពោះការយកចេញ ដោយអនុលោមតាមកថាខណ្ឌទី៣ នៃមាត្រា ២១ ចំពោះការនាំចេញ និងកថាខណ្ឌទី២ នៃមាត្រា ២១ សូន សរុបនៃការប៉ាន់ប្រមាណសំរាប់អាភៀនរបស់ទីកដីនីមួយៗ ត្រូវមានបរិមាណសរុបផងដែរដូចបានបញ្ជាក់នៅក្នុងអនុកថាខណ្ឌ (ក)(ខ)និង(ឃ) កថាខណ្ឌទី ១ នៃមាត្រានេះ ជាមួយនិងតម្រូវការមួយចំនួនក្នុងចំណោមនៃការស្តុកទុកជាក់ស្តែងដែលមានក្នុងដៃនៅថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំ មុន កើនដល់កំរិតដែលបានប៉ាន់ប្រមាណដូចមានចែងក្នុងអនុកថាខ័ណ្ឌ (គ) នៃកថាខ័ណ្ឌ ១ ឬចំនួនដែលបានបញ្ជាក់ស្របតាមអនុកថាខណ្ឌ (ច) កថាខណ្ឌទី ១ នៃមាត្រា នេះ ទោះបីជាខ្ពស់ជាងក៏ដោយ ។

(គ) ចំពោះការយកចេញ ដោយអនុលោមតាមកថាខណ្ឌទី៣ នៃមាត្រា ២១ សរុបនៃការប៉ាន់ប្រមាណចំពោះទីកដីនីមួយៗសំរាប់គ្រឿងញៀនសំយោគនីមួយៗ ត្រូវមានបរិមាណសរុបផងដែរដូចបានបញ្ជាក់នៅក្នុងអនុកថាខណ្ឌ (ក)(ខ)និង(ឃ) កថាខណ្ឌទី ១ នៃមាត្រានេះ ជាមួយនិងតម្រូវការមួយចំនួនក្នុងចំណោមនៃការស្តុកទុកជាក់ស្តែងដែលមានក្នុងដៃនៅ ថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំមុនកើនដល់កំរិតដែលបានប៉ាន់ប្រមាណដូចមានចែងក្នុងអនុកថាខ័ណ្ឌ (គ) នៃកថាខ័ណ្ឌ ១ ឬចំនួនដែលបានបញ្ជាក់ស្របតាមអនុកថាខណ្ឌ (ច) កថាខណ្ឌទី ១ នៃមាត្រានេះ ទោះបីជាខ្ពស់ជាងក៏ដោយ ។

(ឃ)ការប៉ាន់ប្រមាណដែលបានផ្តល់អោយស្របតាមអនុកថាខណ្ឌមុននៃកថាខណ្ឌនេះ ត្រូវបានកែប្រែយ៉ាងត្រឹមត្រូវ ដើម្បីពិចារណាបរិមាណណាមួយដែលត្រូវរឹបអូស និងបន្ទាប់មក ត្រូវបានបញ្ចេញសំរាប់ការប្រើប្រាស់ស្របច្បាប់ ព្រមទាំងបរិមាណណាមួយដែលបានយកចេញពីស្តុកពិសេស សំរាប់តំរូវការរបស់ប្រជាជនស៊ីវិល ។

៣. រដ្ឋណាមួយក្នុងកំឡុងឆ្នាំអាចផ្តល់ការប៉ាន់ប្រមាណបន្ថែម ជាមួយនិងការពន្យល់បញ្ជាក់អំពីកាលៈទេសៈដែលតម្រូវអោយមានការប៉ាន់ប្រមាណបែបនោះផងដែរ ។

៤. ភាគីត្រូវជូនពតិមានដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ អំពីវិធីសាស្ត្រដែលបានប្រើប្រាស់ក្នុងការកំណត់ព័ត៌បរិមាណដែលបានបង្ហាញនៅក្នុងការប៉ាន់ប្រមាណ និងរាល់ការផ្លាស់ប្តូរនៅក្នុងវិធីសាស្ត្រដែលបានបង្ហាញនេះ ។

៥. ដោយដាក់ករតអោយមានការកាត់បន្ថយដូចមានចែងក្នុងកថាខណ្ឌទី៣ នៃមាត្រា ២១ និងការពិចារណាអោយបានត្រឹមត្រូវនូវបទប្បញ្ញត្តិនៃមាត្រា ២១ សូន ការប៉ាន់ប្រមាណមិនត្រូវធ្វើអោយលើសនោះទេ ។

មាត្រា ២០

ស្ថិតក្រឡប់ដែលត្រូវផ្តល់ជូនទៅគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ

១. ភាគីត្រូវផ្តល់ជូនដល់ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ចំពោះដែនដីនីមួយៗរបស់ខ្លួននូវស្ថិតក្រឡប់លើបែបបទដែលបានផ្តល់ជូនតាមវិធី និងបែបបទដែលបានកំណត់ដោយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិលើបញ្ហាដូចខាងក្រោម.:

(ក) ការផលិត ឬធ្វើគ្រឿងញៀន.

(ខ) ការប្រើប្រាស់គ្រឿងញៀនដើម្បីផលិតថ្នាំផ្សេងៗទៀត ការរៀបចំក្នុងតារាង III និងសារធាតុគីមីដែលមិនមានចែងក្នុងអនុសញ្ញានេះនិងការប្រើប្រាស់ដើមរុក្ខជាតិញៀនសំរាប់ការផលិតថ្នាំញៀន

(គ) ការប្រើប្រាស់(សេពៈ)ថ្នាំញៀន

(ឃ)ការនាំចេញ នាំចូលថ្នាំ និងរុក្ខជាតិញៀន

(ង)ការចាប់គ្រឿងញៀន និងការបំផ្លាញចោល

(ច)ការស្តុកគ្រឿងញៀនដូចបានកំណត់នៅថ្ងៃ ៣១ ខែ ធ្នូ នៃឆ្នាំ ដែលពាក់ពន្ធ័នឹងការបញ្ជូនត្រឡប់និង

(ឆ) តំបន់ដាំដើមអាភៀនជាក់លាក់ ។

២. (ក) ស្ថិតក្រឡប់ទាក់ទងនឹងបញ្ហាដែលមានយោងក្នុងអនុកថាខ័ណ្ឌ ១ លើកលែងតែអនុកថាខ័ណ្ឌ(ឃ) ត្រូវរៀបចំធ្វើជារៀងរាល់ឆ្នាំ និងត្រូវផ្តល់ជូនទៅអោយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ មិនអោយលើសពី ថ្ងៃទី ៣០ ខែ មិថុនា នៃឆ្នាំ បន្ទាប់ ដែលពាក់ពន្ធ័ ។

(ខ) ស្ថិតក្រឡប់ទាក់ទងនឹងបញ្ហាដូចមានយោងក្នុងអនុកថាខ័ណ្ឌ (ឃ) នៃកថាខ័ណ្ឌ ១ ត្រូវធ្វើឡើង ៣ ខែម្តង និងត្រូវបញ្ជូនទៅអោយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិក្នុងអំឡុងពេល ១ ខែ បន្ទាប់ពីបញ្ចប់នៃរយៈពេល ៣ ខែ ដែលពាក់ពន្ធ័នោះ ។

៣. ភាគីមិនត្រូវបានតំរូវអោយផ្ដល់ស្ថិតិត្រឡប់ទាក់ទងនឹងការស្ដុកទុកពិសេសទេ ប៉ុន្តែត្រូវផ្ដល់ការបញ្ជូនត្រឡប់ជាចំដោយឡែកទាក់ទងនឹងផ្នាំល្បែងដែលបាននាំចូល ឬ ដែលទទួលបាននៅក្នុងប្រទេស ឬ ដែនដីសំរាប់គោលបំណងពិសេស។ ក៏ដូចជាបរិមាណគ្រឿងល្បែងដែលបានដកចេញមកពីស្ដុកពិសេស ដើម្បីឆ្លើយតបនឹងសេចក្ដីត្រូវការរបស់ប្រជាជនស៊ីវិល ។

មាត្រា ២១

ការដាក់ពិរិតលើការផលិត និង ការនាំចូល

១. បរិមាណសរុបលើគ្រឿងល្បែងនីមួយ។ដែលបានផលិត និង នាំចូលដោយប្រទេសណាមួយ ឬ ដែនដីណាមួយក្នុងឆ្នាំណាមួយ មិនត្រូវអោយលើសបរិមាណសរុបដូចខាងក្រោម:

(ក) បរិមាណដែលបានប្រើប្រាស់ នៅក្នុងកិរិតនៃការចាំន់ប្រមាណដែលពាក់ពន្ធ័សំរាប់ប្រើក្នុងគោលបំណងផ្នែកវេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រ.

(ខ) បរិមាណដែលបានប្រើ នៅក្នុងកិរិតនៃការចាំន់ប្រមាណដែលពាក់ពន្ធ័ ចំពោះការផលិតឱសថផ្សេង។ទៀត សំរាប់ការប្រៀបធ្វើតារាង III និងសារធាតុគីមីដែលមិនមានចែងក្នុងអនុសញ្ញា.

(គ) បរិមាណដែលបាននាំចេញ.

(ឃ) បរិមាណដែលបានបន្ថែមលើស្ដុក ដើម្បីធ្វើអោយស្ដុកនោះស្មើនឹងកិរិតដែលបានកំណត់ក្នុងការចាំន់ប្រមាណដែលពាក់ពន្ធ័ និង.

(ង) បរិមាណដែលតំរូវអោយមាន នៅក្នុងកិរិតនៃការចាំន់ប្រមាណដែលពាក់ពន្ធ័សំរាប់គោលបំណងពិសេស ។

២. ចាប់ពីចំនួននៃបរិមាណដែលបានកំណត់ក្នុងកថាខ័ណ្ឌ១ ត្រូវធ្វើការកាត់បន្ថយនូវបរិមាណទាំងឡាយណាដែលបានរីបអូស ឬបានបញ្ចេញសំរាប់ការប្រើប្រាស់ស្របច្បាប់ ក៏ដូចជាបរិមាណដែលបានយកចេញមកពីស្ដុក ពិសេសសំរាប់បំពេញសេចក្ដីត្រូវការរបស់ប្រជាជនស៊ីវិល ។

៣. ប្រសិនបើគណៈកម្មាធិការត្រួតពិនិត្យគ្រឿងល្បែងអន្តរជាតិរកឃើញថា បរិមាណដែលបានផលិត និងនាំចូលក្នុងឆ្នាំណាមួយ លើសពីបរិមាណដែលបានកំណត់ក្នុងកថាខ័ណ្ឌ ១ តិចជាងការកាត់បន្ថយណាមួយដូចដែលតម្រូវអោយ ដោយកថាខ័ណ្ឌ ២ នៃមាត្រានេះ ការលើសណាមួយដែលបានបង្កើតឡើង ឬនៅសល់នៅចុងឆ្នាំ ត្រូវកាត់បន្ថយបរិមាណដែលត្រូវផលិត ឬនាំចូល និងពី ចំនួននៃការចាំន់ប្រមាណសរុបនៅក្នុងឆ្នាំបន្ទាប់ ដូចបានកំណត់និយមន័យនៅក្នុងកថាខ័ណ្ឌ ២ នៃមាត្រា ១៩ ។

៤. (ក) ប្រសិនបើក្នុងស្ថិតក្រឡប់ស្តីអំពីការនាំចូល ឬ ការនាំចេញ (មាត្រា ២០) បង្ហាញថា បរិមាណដែលបាននាំចេញទៅប្រទេសណាមួយ ឬ ដែនដីណាមួយលើសចំនួននៃការបាន់ប្រមាណសរុបសំរាប់ប្រទេសនោះ ឬ ដែនដីនោះដូចបានកំណត់ក្នុងកថាខ័ណ្ឌ ២ នៃមាត្រា ១៩ ជាមួយនឹងការបន្ថែមលើបរិមាណដែលបានបង្ហាញថានាំចេញ និងបន្ទាប់ពីការកាត់បន្ថយនូវចំនួនដែលលើស ដូចមានកំណត់ក្នុងកថាខ័ណ្ឌ ៣ នៃមាត្រានេះ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ អាចជូនដំណឹងពីអង្គហេតុនេះទៅរដ្ឋទាំងនោះ តាមយោបល់របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិដែលសំរេចថាត្រូវជូនដំណឹងដូច្នោះ.

(ខ) ក្រោយពីបានទទួលការជូនដំណឹង ភាគីមិនត្រូវផ្តល់សិទ្ធិអោយមានការនាំចេញនូវគ្រឿងញៀនដែលពាក់ព័ន្ធនឹងប្រទេសនោះ ឬ ដែនដីនោះ បន្ថែមទៀតទេ ក្នុងកំឡុងឆ្នាំនោះ លើកលែងតែ :

(i) ក្នុងករណីនៃការបាន់ប្រមាណបន្ថែម ត្រូវបានធ្វើឡើងចំពោះប្រទេស ឬដែនដីនោះ ទាក់ទងនឹងបរិមាណដែលបាននាំចូលលើស និង បរិមាណបន្ថែមដែលតំរូវ ឬ

(ii) ក្នុងករណីលើកលែងដែលការនាំចេញ គឺមានសារៈសំខាន់ក្នុងការព្យាបាលជំងឺ ទៅតាមយោបល់របស់រដ្ឋាភិបាលនៃប្រទេសនាំចេញ ។

មាត្រា ២១ ស្តង់
ការដាក់កំរិតនៃការផលិត អាភៀន

១. ការផលិតអាភៀនដោយប្រទេស ឬទឹកដីណាមួយ ត្រូវបានរៀបចំ និងត្រួតពិនិត្យ នៅក្នុងលក្ខណៈបែបណាមួយដែលបានថា បរិមាណដែលបានផលិតនៅក្នុងមួយឆ្នាំណាមួយ តាមដែលអាចធ្វើទៅបាននឹងមិនត្រូវអោយលើសពីការបាន់ប្រមាណអាភៀនដែលត្រូវផលិតដូចបានបាន់ប្រមាណ ស្របតាមកថាខ័ណ្ឌទី ១ (ច) នៃមាត្រា ១៩ ។

២. ដោយផ្អែកទៅលើពតិមានជាមូលដ្ឋាននៃការប្រើប្រាស់អំណាចរបស់ខ្លួន ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ ប្រសិនបើគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិរកឃើញថា ភាគី មួយដែលបានដាក់ជូននូវការបាន់ប្រមាណ ស្របតាមកថាខណ្ឌទី ១ (ច) នៃមាត្រា ១៩ មិនបានកំណត់អាភៀនដែលបានផលិតនៅក្នុងព្រំដែនរបស់ខ្លួន ដើម្បីអោយប្រែរួមស្របច្បាប់ ដោយអនុលោមទៅតាមការបាន់ប្រមាណដែលពាក់ព័ន្ធ ហើយ ចំនួនជាក់លាក់មួយនៃអាភៀនដែលបានផលិត ទោះបីជាស្របច្បាប់ ឬ មិនស្របច្បាប់នៅក្នុងព្រំដែននៃភាគីមួយនោះ ត្រូវបានដាក់ចូលទៅ

ក្នុងការចរាចរខុសច្បាប់ បន្ទាប់ពីការសិក្សានៃការពន្យល់របស់ភាគីពាក់ព័ន្ធ ដែលនឹងត្រូវបានដាក់ជូនទៅកាន់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ នៅក្នុងរយៈពេល ១ ខែ បន្ទាប់ពីការជូនដំណឹងនៃការរកឃើញខាងលើ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិអាចសំរេចដើម្បីយកចេញទាំងអស់ ឬមួយផ្នែកនៃចំនួនដែលបានមកពីបរិមាណដើម្បីផលិត និងបានមកពីចំនួនសរុបនៃការចាំន់ប្រមាណដូចដែលបានកំណត់នៅក្នុងកថាខ័ណ្ឌទី២ (ខ) នៃមាត្រា ១៩ សំរាប់ឆ្នាំបន្ទាប់ ដែលក្នុងនោះ ការយកចេញទាំងនោះ អាចត្រូវបានបំពេញផ្នែកបច្ចេកទេស ការពិចារណាទៅលើរដូវនៃឆ្នាំ និងការប្តេជ្ញាចិត្តដែលមានកិច្ចសន្យាចំពោះការនាំចេញអាភៀន ។ ការសំរេចចិត្តនេះ នឹងមានប្រសិទ្ធភាព ៩០ ថ្ងៃ បន្ទាប់ពីភាគីដែលពាក់ព័ន្ធ ត្រូវបានជូនដំណឹងនោះ ។

៣. បន្ទាប់ពីការជូនដំណឹងដល់ភាគីពាក់ព័ន្ធនៃការចំរេចចិត្ត ដែលបានប្រកាន់យកស្របទៅតាមកថា-ខ័ណ្ឌទី២ខាងលើចំពោះការយកចេញ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិនឹងពិភាក្សាជាមួយភាគីនោះ ក្នុងគោលបំណងដើម្បីដោះស្រាយសភាពការណ៍ គួរជាទីពេញចិត្ត ។

៤. ប្រសិនបើសភាពការណ៍មិនត្រូវបានដោះស្រាយគួរជាទីពេញចិត្តទេ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ អាចប្រើប្រាស់បទប្បញ្ញត្តិនៃមាត្រា ១៤ ដែលមានលក្ខណៈត្រឹមត្រូវ ។

៥. នៅក្នុងការសំរេចចិត្តរបស់ខ្លួនចំពោះការយកចេញ ដោយអនុលោមតាមកថាខ័ណ្ឌទី ២ ខាងលើ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ នឹងពិចារណា មិនត្រឹមតែកាលៈទេសៈដែលពាក់ព័ន្ធទាំងអស់ ដោយរួមបញ្ចូលទាំងអ្វីដែលបណ្តាលអោយមានបញ្ហាការចរាចរខុសច្បាប់ ស្របតាមកថាខ័ណ្ឌ ទី ២ ខាងលើប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងវិធានការត្រួតពិនិត្យថ្មីៗដែលពាក់ព័ន្ធផ្សេងៗទៀតផងដែរដែលអាចត្រូវបានអនុម័តដោយភាគី ។

មាត្រា ២២

បទប្បញ្ញត្តិពិសេសដែលអាចអនុវត្តបានចំពោះការដាំដុះ

១. នៅពេលដែលមានលក្ខខណ្ឌចាំបាច់ក្នុងប្រទេស ឬដែនដីមួយរបស់ភាគី ត្រូវហាមប្រាមដល់ការដាំដុះដើមអាភៀន ដើមកូកា ឬដើមកញ្ឆាដែលជាវិធានការមួយសមស្រប តាមគំនិតរបស់ខ្លួន ដើម្បីការពារសុខភាព និងសុខុមាលភាពសាធារណៈ និងការចប់ស្អាត់ការបង្វែរគ្រឿងញៀនចូលទៅក្នុងការចរាចរខុសច្បាប់ ភាគីដែលពាក់ព័ន្ធ ត្រូវធ្វើការហាមឃាត់ការដាំដុះទាំងនោះ ។

២. ការហាមឃាត់ការដាំដើមអាភៀន ឬដើមកញ្ឆារបស់ភាគីមួយ ត្រូវចាត់វិធានការណ៍អោយបានសមស្រប ដើម្បីរឹបអូសយកដើមរុក្ខជាតិទាំងនោះដែលដាំដោយខុសច្បាប់ និងបំផ្លាញដើមរុក្ខជាតិទាំងនោះចោល លើកលែងតែបរិមាណបន្តិចបន្តួចដែលតំរូវអោយមានដោយភាគី សំរាប់គោលបំណងផ្នែកការស្រាវជ្រាវ និង វិទ្យាសាស្ត្រ ។

មាត្រា ២៣
ភ្នាក់ងារអាភៀនជាតិ

១. ភាគីមួយដែលអនុញ្ញាតអោយមានការដាំដុះដើមអាភៀន សំរាប់ការផលិតអាភៀន ប្រសិនបើមិនទាន់មាននៅឡើយទេ ត្រូវបង្កើត និងរក្សាភ្នាក់ងាររដ្ឋាភិបាលមួយ ឬ ច្រើន (ដែលនៅផ្នែកខាងក្រោយនៃមាត្រានេះ ហៅកាត់ថាជាទីភ្នាក់ងារ) សំរាប់អនុវត្តន៍ភារកិច្ចដែលតំរូវ ដោយអនុលោមតាមមាត្រានេះ ។

២. ភាគីនីមួយៗត្រូវអនុវត្តន៍បទប្បញ្ញត្តិខាងក្រោម ចំពោះការដាំដុះដើមអាភៀន ការផលិតអាភៀន និង អាភៀន :

(ក) ភ្នាក់ងារត្រូវដាក់ទីតាំងដែលក្នុងទីតាំងនោះ និង ចំណែកដីនោះ បានទទួលការអនុញ្ញាតអោយដាំដើមអាភៀន ដើម្បីផលិតអាភៀន ។

(ខ) មានតែការដាំដុះដែលទទួលអាជ្ញាប័ណ្ណពីភ្នាក់ងារនេះទេ ទើបត្រូវបានអនុញ្ញាតអោយមានការពាក់ពន្ធ័នៅក្នុងការដាំដុះនេះ ។

(គ) អាជ្ញាប័ណ្ណនីមួយៗ ត្រូវបញ្ជាក់អោយបានច្បាស់ពីទំហំដីដែលបានទទួលការអនុញ្ញាតអោយដាំដុះ ។

(ឃ) អ្នកដាំដុះដើមអាភៀនទាំងអស់ ត្រូវតំរូវអោយធ្វើការបញ្ជូនដើមអាភៀនទាំងអស់ទៅអោយភ្នាក់ងារ។ ភ្នាក់ងារត្រូវទិញ និងកាន់កាប់ភោគផលទាំងនោះអោយបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ដោយមិនអោយលើសពីរយៈពេល ៤ ខែ ក្រោយពីការបញ្ចប់ការប្រមូលផល ។

(ង) ចំពោះអាភៀន ភ្នាក់ងារត្រូវមានសិទ្ធិផ្តាច់បុរ ក្នុងការនាំចូល នាំចេញ ធ្វើជំនួញលក់ដុំ និងរក្សាទុកក្នុងស្តុកចំពោះអ្វី ដែលនៅសល់ពីការកាន់កាប់របស់អ្នកផលិតអាភៀន អាល់កាលូអ៊ីដអាភៀន ប្រើក្នុងវេជ្ជសាស្ត្រ ឬអាភៀនផ្សំ ។ ភាគីមិនចាំបាច់ពង្រីកសិទ្ធិផ្តាច់មុខនេះ ចំពោះអាភៀនប្រើក្នុងវេជ្ជសាស្ត្រ និងអាភៀនផ្សំនោះទេ ។

៣. តួនាទីរបស់រដ្ឋាភិបាលដូចមានយោងក្នុងកថាខណ្ឌ ២ ត្រូវអនុវត្តន៍ដោយភ្នាក់ងារបស់រដ្ឋាភិបាលមួយ ប្រសិនបើរដ្ឋធម្មនុញ្ញរបស់ភាគីដែលពាក់ពន្ធ័ អនុញ្ញាតអោយធ្វើបែបនោះ ។

មាត្រា ២៥

ការដាក់កិរិតលើការផលិតអាភៀនសំរាប់ការធ្វើជនូញអន្តរជាតិ

១. (ក) ប្រសិនបើភាគីណាមួយ មានបំណងផ្តួចផ្តើមផលិតអាភៀន ឬ បង្កើនការផលិតអាភៀន ដែលមានស្រាប់ ខ្លួនត្រូវពិចារណាលើសេចក្តីត្រូវការអាភៀនជារួមរបស់ពិភពលោក ដោយស្រប តាមការចាំន់ប្រមាណដែលបានបោះពុម្ពផ្សព្វផ្សាយ ដោយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន អន្តរជាតិ ដើម្បីអោយការផលិតអាភៀនរបស់ភាគីនោះមិនធ្វើអោយមានផលិតផលអាភៀន លើសលុបនៅក្នុងពិភពលោក ។

(ខ) ភាគីមួយមិនត្រូវអនុញ្ញាតអោយមានការផលិតអាភៀន ឬ បង្កើនការផលិតអាភៀនដែលមាន ស្រាប់ទេ ប្រសិនបើយល់ឃើញថា ការផលិត ឬការបង្កើនការផលិតនៅក្នុងដែនដីរបស់ខ្លួន អាច បណ្តាលអោយមានការចរាចរអាភៀនខុសច្បាប់ ។

២. (ក) ដោយយោលទៅតាមកថាខ័ណ្ឌ ១ ភាគីមិនបានផលិតអាភៀនសំរាប់នាំចេញ ដល់ថ្ងៃ ១ ខែ មករា ១៩៦១ មានបំណងនាំអាភៀនដែលខ្លួនផលិត ចេញក្នុងបរិមាណមិនលើសពី ៥ តោនប្រចាំឆ្នាំ ខ្លួនត្រូវជូនដំណឹងដល់ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ដោយធ្វើការបញ្ជាក់ជូន ជាមួយនឹងការជូនដំណឹងនោះ នូវពត៌មានដូចជា :

(i) ការត្រួតពិនិត្យជាចាំបាច់ ដូចដែលតំរូវអោយមានដោយអនុសញ្ញានេះ ទាក់ទងនឹងអាភៀន ដែលត្រូវផលិត និងនាំចេញ និង.

(ii) ឈ្មោះរបស់ប្រទេសមួយ ឬច្រើន ដែលប្រទេសនោះរំពឹងថានាំចេញនូវគ្រឿងញៀន ហើយ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ អាចឯកភាពលើការជូនដំណឹងនោះ ថែមទាំង អាចផ្តល់អនុសាសន៍ដល់ភាគីថា ខ្លួនមិនពាក់ពន្ធ័ក្នុងការផលិតគ្រឿងញៀនដើម្បីនាំចេញនោះទេ ។

(ខ) ក្នុងករណីភាគីណាមួយ ក្រៅពីភាគីដែលមានយោងក្នុងកថាខ័ណ្ឌ ៣ មានបំណងចង់ផលិត អាភៀនដើម្បីនាំចេញក្នុងបរិមាណលើសពីប្រាំតោនក្នុងមួយឆ្នាំ ខ្លួនត្រូវជូនដំណើងដល់ក្រុមប្រឹក្សា ដោយមានការបញ្ជាក់ក្នុងការជូនដំណឹងនោះ នូវពត៌មានដូចតទៅ :

(i) បរិមាណដែលបានចាំន់ប្រមាណថា ត្រូវផលិតដើម្បីនាំចេញ.

(ii) ការត្រួតពិនិត្យអាវុធដែលនៅសល់ ឬអាវុធដែលបានស្នើថា នឹងផលិត,

(iii) ឈ្មោះរបស់ប្រទេសមួយ ឬច្រើនដែលប្រទេសនោះ រំពឹងថានាំចេញនូវអាវុធទាំងនោះ ហើយ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ អាចធ្វើការឯកភាពលើការជូនដំណឹងនោះ ថែមទាំង អាចផ្តល់អនុសាសន៍ដល់ភាគីនោះថា ខ្លួនមិនពាក់ពន្ធ័នឹងការផលិតអាវុធ ដើម្បីនាំចេញ នោះទេ ។

៣. ទោះបីជាមានបញ្ញត្តិនៃអនុកថាខ័ណ្ឌ (ក) និង (ខ) នៃកថាខ័ណ្ឌ ២ ភាគីមួយដែលបាននាំចេញ អាវុធដែលខ្លួនបានផលិតក្នុងអំឡុងពេល ១០ ឆ្នាំមុនភ្លាមៗ មុនថ្ងៃទី១ ខែ មករា ឆ្នាំ ១៩៦១ ប្រទេសនោះអាចបន្ត នាំចេញអាវុធដែលខ្លួនផលិត ។

៤. (ក) ភាគីមួយមិនត្រូវនាំអាវុធចេញពីប្រទេស ឬ ដែនដីណាមួយទេ លើកលែងតែអាវុធ ត្រូវបានផលិតនៅ:

(i) ភាគីមួយដូចមានចែងក្នុងកថាខ័ណ្ឌ ៣

(ii) ភាគីដែលបានជូនដំណឹងដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ដូចមាន ចែងក្នុងអនុកថាខ័ណ្ឌ (ក) នៃកថាខ័ណ្ឌ ២ ឬ

(iii) ភាគីដែលបានទទួលការឯកភាពពី គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ដូច មានចែងក្នុងអនុកថាខ័ណ្ឌ (ខ) នៃកថាខ័ណ្ឌ ២ ។

(ខ) ទោះបីជាមានអនុកថាខ័ណ្ឌ (ក) នៃកថាខ័ណ្ឌនេះ ភាគីមួយអាចនាំចូលអាវុធដែលបាន ផលិតក្នុងប្រទេសណាមួយដែលបានផលិត និង នាំអាវុធចេញក្នុងអំឡុងពេល ១០ ឆ្នាំមុនថ្ងៃទី ១ ខែ មករា ១៩៦១ ប្រសិនបើប្រទេសនោះបានបង្កើតឡើង និងរក្សាប្រពន្ធ័ត្រួតពិនិត្យថ្នាក់ជាតិមួយ ឬ ភ្នាក់ងារសំរាប់ ប់រើលើគោលប៉ំណងដែលមានចែងក្នុងមាត្រា ២៣ និងមានមធ្យោបាយប្រកបដោយប្រសិទ្ធភាព ក្នុងការ ធានាថា អាវុធដែលខ្លួនផលិត មិនត្រូវបង្វែរទៅជាការចរាចរខុសច្បាប់ទេ ។

៥. បញ្ញត្តិនៃមាត្រានេះមិនទប់ស្កាត់ភាគីណាមួយពី:

(ក) ការផលិតអាវុធក្រប់គ្រាន់សំរាប់បំរើសេចក្តីត្រូវការរបស់ខ្លួន ឬ

(ខ) ការនាំចេញអាវុធដែលចាប់បានមកពីការចរាចរខុសច្បាប់

ទៅកាន់ភាគីមួយផ្សេងទៀតនៅក្នុងការទំនាក់ទំនងជាមួយនិងសេចក្តីតម្រូវការនៃអនុសញ្ញានេះ ។

មាត្រា ២៥

ការត្រួតពិនិត្យដើមអាកៀនស្ងួត

១. ភាគីមួយដែលអនុញ្ញាតអោយមានការដាំដុះដើមអាកៀនសំរាប់គោលបំណង ក្រៅពីការផលិតអាកៀន ត្រូវចាត់វិធានការចាំបាច់ដើម្បីធានាអោយបានថា :

(ក) អាកៀនទាំងនោះមិនត្រូវផលិតចេញពីដើមអាកៀនទេ ហើយ

(ខ) ការផលិតឱសថចេញពីដើមអាកៀនស្ងួត ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យអោយបានត្រឹម ត្រូវបំផុត ។

២. ភាគីនានាត្រូវប្រើប្រាស់ដើមអាកៀនស្ងួតតាមប្រពន្ធ័នៃអាជ្ញាប័ណ្ណនាំចូល និងការអនុញ្ញាតនាំចេញដូចមានចែងក្នុងមាត្រា ៣១ ពីកថាខ័ណ្ឌ ៤ ដល់ ១៥ ។

៣. ភាគីត្រូវផ្តល់ពត៌មានស្ថិតិអំពីការនាំចេញ និងការនាំចូលដើមអាកៀនស្ងួត ដូចសេចក្តីត្រូវការលើគ្រឿងញៀនដែរ តាមមាត្រា ២០ កថាខ័ណ្ឌ ១ (ឃ) និង ២ (ខ) ។

មាត្រា ២៦

ដើមកូកា និង ស្លឹកកូកា

១ ប្រសិនប្រើភាគីមួយអនុញ្ញាតអោយមានការដាំដុះដើមកូកា ភាគីនោះត្រូវប្រើប្រាស់ប្រពន្ធ័ត្រួតពិនិត្យស្លឹកកូកា ដូចមានចែងក្នុងមាត្រា ២៣ ទាក់ទងនឹងការត្រួតពិនិត្យដើមអាកៀន ក៏ប៉ុន្តែដោយគោរពទៅតាមកថាខ័ណ្ឌ ២ (ឃ) នៃមាត្រានោះ សេចក្តីត្រូវការដែលដាក់ទៅលើភ្នាក់ងារដែលមានយោងនៅទីនេះ ត្រូវតែយកជាកម្មសិទ្ធិដើមរុក្ខជាតិនោះ អោយបានកាន់តាប់តាមដែលអាចធ្វើទៅបានបន្ទាប់ពីការបញ្ចប់ការប្រមូលផល ។

២. ភាគីត្រូវធ្វើអោយអស់លទ្ធភាពចំពោះការដីកប្លុសគល់នៃគុម្ពកូកាដែលដុះដោយយថាហេតុ ។ ពួកគេត្រូវបំផ្លាញគុម្ពកូកា ទាំងនោះចោល ប្រសិនបើមានការដាំដុះខុសច្បាប់ ។

មាត្រា ២៧

បទប្បញ្ញត្តិបន្ថែមទាក់ទងនឹងស្លឹកកូកា

១. ភាគីអាចអនុញ្ញាតអោយប្រើប្រាស់ស្លឹកកូកា ដើម្បីរៀបចំធ្វើជាភ្នាក់ងាររសជាតិ ដែលមិនត្រូវមានសារធាតុអាល់កាឡូអ៊ីដ និងតាមការចាំបាច់នៃការប្រើប្រាស់នីមួយៗ អាចអនុញ្ញាតអោយមានការផលិត ការនាំចូល ការធ្វើដំនូញ និងកម្មសិទ្ធិលើស្លឹកទាំងនោះ ។

២. ភាគីត្រូវផ្តល់ការចាំន់ប្រមាណដាច់ដោយឡែកពីគ្នា (មាត្រា ១៩) និង ពត៌មានលើស្ថិតិ (មាត្រា ២០) ទាក់ទងនឹងស្លឹកកូកា សំរាប់យកទៅផ្សំធ្វើជាភ្នាក់ងាររសជាតិ លើកលែងតែថាស្លឹកកូកាដូចគ្នាត្រូវយកទៅប្រើប្រាស់សំរាប់ការដកសារធាតុអាល់កាឡូអ៊ីត និង ភ្នាក់ងាររសជាតិ និង មានការបកស្រាយពន្យល់ក្នុងការចាំន់ប្រមាណ និង ពត៌មានស្ថិតិ ។

មាត្រា ២៨

ការត្រួតពិនិត្យកញ្ចា

១. ប្រសិនបើភាគីមួយអនុញ្ញាតអោយមានការដាំដុះដើមកញ្ចាសំរាប់ការផលិតកញ្ចា ឬជំរកញ្ចា ភាគីនោះត្រូវប្រើប្រាស់ប្រពន្ធ័ត្រប់ត្រង ដូចមានចែងក្នុងមាត្រា ២៣ ទាក់ទងនឹងការត្រួតពិនិត្យដើមអាភៀន ។

២. អនុសញ្ញានេះ មិនត្រូវប្រើប្រាស់ចំពោះការដាំដុះដើមកញ្ចាផ្តាច់មុខ សំរាប់បំរើគោលបំណងឧស្សាហ៍កម្ម (ដើម ឬ គ្រាប់) ឬការធ្វើពិសោធន៍ផ្នែកកសិកម្មទេ ។

៣. ភាគីត្រូវអនុម័តវិធានការទាំងនេះទៅតាមការចាំបាច់ ដើម្បីបង្ការការប្រើប្រាស់ខុស និង ការចរាចរខុសច្បាប់នូវស្លឹករបស់ដើមកញ្ចា ។

មាត្រា ២៩

ការផលិត

១. ភាគីត្រូវតំរូវថា ការផលិតឱសថត្រូវស្ថិតនៅក្រោមអាជ្ញាប័ណ្ណ លើកលែងតែការផលិតនោះធ្វើឡើងដោយសហគ្រាសរបស់រដ្ឋមួយ ឬច្រើន ។

២. ភាគីត្រូវ :

(ក) ត្រួតពិនិត្យមនុស្ស និង សហគ្រាសទាំងអស់ដែលកំពុងអនុវត្តន៍ ឬដែលពាក់ពន្ធ័ក្នុងការផលិតឱសថ

(ខ) ត្រួតពិនិត្យតាមអាជ្ញាបណ្ណ ទូវទីតាំង និង ទីកន្លែងនានាដែលទីកន្លែងទាំងនោះ ការផលិតឱសថ អាចមានដំណើរការ និង

(គ) តំរូវអោយអ្នកផលិតឱសថដែលមានអាជ្ញាប័ណ្ណ ទទួលការអនុញ្ញាតតាមពេលវេលា ដោយមានការបញ្ជាក់អំពីប្រភេទ និង៍បរិមាណឱសថដែលពួកគេមានសិទ្ធិផលិត ។ ទោះជាដូច្នោះក៍ដោយ ការអនុញ្ញាតតាមពេលមិនចាំបាច់ត្រូវការអោយមានការត្រៀបចំទេ ។

៣. ភាគី ត្រូវទប់ស្កាត់ការប្រមូលផ្តុំក្នុងការកាន់កាប់របស់អ្នកផលិត បរិមាណគ្រឿងញៀន និងដើមអាភៀនសួតលើសពីអ្វីដែលបានតំរូវសំរាប់ដំណើរការជំនួញធម្មតា ដោយពិចារណាទៅលើសេចក្តីត្រូវការរបស់លក្ខខ័ណ្ឌទីផ្សារ ។

មាត្រា ៣០

ជំនួញ និងការចែកចាយ

១. (ក) ភាគីត្រូវកំណត់ថាការធ្វើជំនួញ និងការចែកចាយគ្រឿងញៀនត្រូវស្ថិតនៅក្រោមអាជ្ញាប័ណ្ណ លើកលែងតែក្នុងករណីដែលការធ្វើជំនួញ ឬការចែកចាយនោះ ធ្វើឡើងដោយសហគ្រាសរដ្ឋមួយ ឬ ច្រើន ។

(ខ) ភាគីត្រូវ:

(i) ត្រួតពិនិត្យលើមនុស្ស និងសហគ្រាសទាំងអស់ដែលកំពុងអនុវត្តន៍ ឬពាក់ពន្ធ័ក្នុងការធ្វើជំនួញ ឬការចែកចាយគ្រឿងញៀន ។

(ii) ត្រួតពិនិត្យតាមអាជ្ញាប័ណ្ណនូវទីតាំង និងទីកន្លែងដែលការធ្វើជំនួញ និងការចែកចាយ កំពុងមានសកម្មភាព។ លក្ខខ័ណ្ឌនៃការចេញអាជ្ញាប័ណ្ណ មិនចាំបាច់អនុវត្តន៍ចំពោះការត្រៀបចំនោះទេ ។

(iii) បញ្ញត្តិនៃអនុកថាខ័ណ្ឌ (ក) និង(ខ) ដែលទាក់ទងនឹងការចេញអាជ្ញាប័ណ្ណ មិនអនុវត្តន៍ចំពោះបុគ្គលដែលបានទទួលការអនុញ្ញាតពេញលេញក្នុងការអនុវត្តន៍ និងនៅពេលកំពុងទទួលបន្ទុកការព្យាបាល ឬបច្ចេកវិជ្ជាឡើយ ។

២. ភាគីក៍ត្រូវ :

(ក) បង្ហាញការសន្សំការប្រមូលទុកក្នុងការកាន់កាប់របស់អ្នកជំនួញ អ្នកចែកចាយ សហគ្រាសរដ្ឋ ឬ បុគ្គលដែលបានទទួលសិទ្ធិពេញលេញដូចមានយោងខាងលើ នូវបរិមាណនៃគ្រឿងញៀន និង ដើមគ្រឿងញៀនសួត ដែលលើសពីអ្វីដែលបានកំណត់ក្នុងការប្រតិបត្តិជំនួញធម្មតា ដែលទាក់ទងទៅនឹងលក្ខខណ្ឌតំរូវការរបស់ទីផ្សារ. និង

(ខ) (i) តំរូវអោយមានវេជ្ជបញ្ជាផ្ទៃកថ្នាំពេទ្យ សំរាប់ការផ្តត់ផ្តង់ ឬ ការបញ្ចេញថ្នាំទៅអោយបុគ្គលឯកជន ។ សេចក្តីតំរូវនេះ មិនត្រូវអនុវត្តន៍ចំពោះថ្នាំណាដែលបុគ្គលអាច ទទួលបានប្រើប្រាស់ បញ្ចេញ ឬ គ្រប់គ្រងពេញច្បាប់ ជាមួយនឹងសិទ្ធិពេញលេញរបស់គេ ក្នុងមុខងារព្យាបាលដែលមានការអនុញ្ញាតត្រឹមត្រូវ ហើយស្របនឹងច្បាប់ និង

(ii) ប្រសិនបើភាគីយល់ថា វិធានការទាំងនេះជាការចាំបាច់ ឬសមស្រប តំរូវថា វេជ្ជបញ្ជាចំពោះថ្នាំញៀនក្នុងតារាង I ត្រូវសរសេរលើបែបបទផ្លូវការ ដែលត្រូវបោះពុម្ពចេញជាកូនសៀវភៅដោយអាជ្ញាធររដ្ឋាភិបាលមានសមត្ថកិច្ច ឬ ដោយសមាគមន៍ជំនាញដែលបានទទួលសិទ្ធិអនុញ្ញាត ។

៣. វាជាការចង់បាន គឺថា ភាគីនានាតំរូវថាត្រូវកើ្តឡាយលាក់អក្សរក្នុងការផ្តល់ថ្នាំញៀន ការផ្សព្វផ្សាយពាណិជ្ជកម្ម អំពីអត្ថបទគ្រប់ប្រភេទ ឬការអត្ថាធិប្បាយដែលទាក់ទងនឹងថ្នាំញៀន និងបានប្រើក្នុងគោលបំណងធ្វើពាណិជ្ជកម្ម ការរុំនៅខាងក្នុងកញ្ចប់ដែលនៅក្នុងកញ្ចប់នោះ មានថ្នាំញៀន និង ផ្លាកយីហោដែលគ្រឿងញៀននោះនឹងត្រូវលក់ បញ្ជាក់អំពីឈ្មោះ ត្មានម្ចាស់កម្មសិទ្ធិអន្តរជាតិ ដែលទំនាក់ទំនងដោយអង្គការសុខភាពពិភពលោក ។

៤. ប្រសិនបើភាគីមួយចាត់ទុកថាវិធានការនេះមានការចាំបាច់ ឬ ចង់បានវិធានការនេះ ខ្លួនត្រូវតំរូវថា ផ្ទៃកខាងក្នុងកញ្ចប់ដែលមានថ្នាំញៀន ឬសំបករុំត្រូវមានខ្សែពណ៌ក្រហមពីរខុបដែលអាចមើលឃើញយ៉ាងច្បាស់ ។ ការរុំកញ្ចប់ផ្ទៃកខាងក្រៅ ដែលនៅក្នុងកញ្ចប់នោះ ថ្នាំញៀនដែលផ្ទុក មិនត្រូវមានខ្សែពណ៌ក្រហមខុបទេ ។

៥. ភាគីមួយត្រូវតំរូវថា ផ្លាកសញ្ញាដែលដាក់លក់ថ្នាំត្រូវបង្ហាញពីប្រភេទថ្នាំជាទម្ងន់ ឬជាភាគរយ ។ តំរូវការពត៌មានលើផ្លាកសញ្ញានេះ មិនត្រូវអនុវត្តន៍ចំពោះថ្នាំដែលបានបញ្ចេញទៅអោយបុគ្គល តាមរយៈវេជ្ជបញ្ជានោះទេ ។

៦. បញ្ញត្តិនៃកថាខ័ណ្ឌ ២ និង ៥ មិនត្រូវអនុវត្តន៍ចំពោះការលក់រាយ ឬការចែកចាយរាយគ្រឿងញៀន ក្នុងតារាង II ទេ ។

មាត្រា ៣១
បញ្ញត្តិពិសេសទាក់ទងនឹងជំនួញអន្តរជាតិ

១. ភាគីទាំងឡាយ មិនត្រូវអនុញ្ញាតអោយមានការនាំចេញគ្រឿងញៀនទៅប្រទេស ឬដែនដីណាមួយនោះទេ ប្រសិនបើខ្លួនដឹង លើកលែងតែ :

(ក) យោងទៅតាមច្បាប់ និង គោលការណ៍ដែលប្រទេស ឬ ដែនដីនោះ និង

(ខ) ក្នុងកិរិតចំនួនសរុបក្នុងការបាន់ប្រមាណចំពោះប្រទេសនោះ ឬ ដែនដីនោះដូចបានកំណត់ក្នុងកថាខ័ណ្ឌទី ២ នៃមាត្រា ១៩ ជាមួយនិងការបូកបន្ថែមលើចំនួនដែលគ្រោងថា នឹងនាំចេញឡើងវិញ។

២. ភាគីត្រូវអនុវត្តន៍ក្នុងកំពង់ផែ និងតំបន់រួចពន្ធ(សេរី) ដូចការត្រួតមើល និងការត្រួតពិនិត្យនៅក្នុងផ្នែកផ្សេង១ទៀតនៃដែនដីរបស់ពួកគេដែរ ទោះបីជាយ៉ាងណាក៏ដោយ ដោយចែងថា ពួកគេអាចអនុវត្តវិធានការខ្ទាំងក្លាបន្ថែមទៀត ។

៣. ភាគីត្រូវ :

(ក) ត្រួតពិនិត្យតាមអាជ្ញាប័ណ្ណនាំចេញ និងនាំចូលគ្រឿងញៀន លើកលែងតែក្នុងករណីការនាំចេញ ឬនាំចូលថ្វើឡើងដោយសហគ្រាសរបស់រដ្ឋ ។

(ខ) ត្រួតពិនិត្យមនុស្ស និង សហគ្រាសទាំងអស់ដែលកំពុងអនុវត្តន៍ ឬជាប់ពាក់ពន្ធ័ក្នុងការនាំចេញ ឬ នាំចូល ។

៤. (ក) ភាគីនីមួយ១ដែលអនុញ្ញាតអោយមានការនាំចេញ ឬនាំចូលគ្រឿងញៀន ត្រូវតំរូវអោយមានការផ្តល់សិទ្ធិអនុញ្ញាតអោយនាំចេញ ឬនាំចូលដាច់ដោយឡែកមួយ ដើម្បីទទួលសំរាប់ នាំចេញ ឬនាំចូលគ្រឿងញៀនទាំងនោះ ទោះបីជាមានគ្រឿងញៀនមួយមុខ ឬច្រើនមុខក៏ដោយ ។

(ខ) ការអនុញ្ញាតនេះត្រូវបញ្ជាក់ពីឈ្មោះគ្រឿងញៀន ឈ្មោះដែលមិនមែនជាប្លាកយីហោជំនួញអន្តរជាតិប្រសិនបើមាន បរិមាណដែលនឹងត្រូវនាំចូល ឬនាំចេញ និងឈ្មោះ និង

អាសយដ្ឋានរបស់អ្នកនាំចេញ និងនាំចូល និងត្រូវកំណត់ពីរយៈពេលដែលការនាំចេញ ឬ ការនាំចូលនោះ អាចប្រព្រឹត្តឡើង ។

(គ) សិទ្ធិអនុញ្ញាតនាំចេញក៏ត្រូវបញ្ជាក់ផងដែរពីចំនួន និង ការបរិច្ឆេទនៃប័ណ្ណនាំចូល (កថាខ័ណ្ឌ ៥) និង អ្នកដែលចេញសិទ្ធិអនុញ្ញាតនោះ ។

(ឃ) សិទ្ធិអនុញ្ញាតនៃការនាំចូល អាចអនុញ្ញាតអោយមានការនាំចូល ច្រើនជាងមួយដង ។

៥. មុនការចេញសិទ្ធិអោយនាំចេញ ភាគីត្រូវតំរូវអោយមានប័ណ្ណអនុញ្ញាតអោយនាំចូល ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសដែលនាំចូល ឬដែនដី ហើយត្រូវកំណត់ថា ការនាំគ្រឿងញៀនចូលដូចមានចែងនេះ ត្រូវបានទទួលការឯកភាព ហើយប័ណ្ណទាំងនោះ ត្រូវវៀបចំធ្វើឡើងដោយជននោះ ឬ ទីតាំងដែលបានដាក់ពាក្យសុំសិទ្ធិធ្វើការនាំចូល ។ ភាគី ត្រូវធ្វើការតាមដានអោយបានយ៉ាងជិតដល់ នូវបែបបទនៃប័ណ្ណនាំចូលដែលគណៈកម្មការបានឯកភាព ។

៦. ឯកសារចម្ងងមួយច្បាប់នៃការអនុញ្ញាតអោយនាំចេញ ត្រូវដាក់អមតាមការផ្ញើបញ្ជូនរបស់រាល់លើក ហើយរដ្ឋាភិបាលដែលចេញសិទ្ធិអនុញ្ញាតអោយនាំចេញនោះ ត្រូវបញ្ជូនឯកសារ ចម្ងងមួយច្បាប់ទៅអោយប្រទេស ឬដែនដីដែលត្រូវនាំចូល ។

៧. (ក) រដ្ឋាភិបាល និងដែនដីដែលនាំចូល នៅពេលដែលការនាំចូលមានប្រសិទ្ធភាព ឬនៅពេលដែលរយៈពេលកំណត់នៃការនាំចូលត្រូវបានបញ្ចប់ ត្រូវបញ្ជូនត្រឡប់សិទ្ធិអនុញ្ញាតអោយនាំចេញ ជាមួយនឹងការបញ្ជាក់របស់ខ្លួន ទៅអោយរដ្ឋាភិបាលនៃប្រទេស ឬដែនដីដែលបាននាំចេញ ។

(ខ) សេចក្តីបញ្ជាក់ត្រូវកំណត់ពីបរិមាណដែលបាននាំចូលអោយបានពិតប្រាកដ ។

(គ) ប្រសិនបើមានបរិមាណតិចជាងអ្វីដែលមានកំណត់ក្នុងសិទ្ធិអនុញ្ញាតនាំចេញ ដែលត្រូវបាននាំចេញពិតប្រាកដ បរិមាណដែលបាននាំចេញនោះ ត្រូវបញ្ជាក់អោយបានច្បាស់លាស់ដោយអាជ្ញាធរមានសមត្ថកិច្ចលើសិទ្ធិអនុញ្ញាតនាំចេញ និងលើឯកសារផ្លូវការផ្សេងៗទៀត ។

៨. ការនាំចេញឥវ៉ាន់ទៅប្រអប់សំបុត្រប្រៃសណីយ៍ ឬធនាគារដែលមានគណនីរបស់ភាគីមួយ ក្រៅពីភាគីដែលបានដាក់ឈ្មោះក្នុងសិទ្ធិអនុញ្ញាតអោយនាំចេញ ត្រូវបានហាមឃាត់ ។

៩. ការនាំចេញឥវ៉ាន់ទៅដាក់ក្នុងទីតាំងផ្ទុកទំនិញរួចជួល ត្រូវបានហាមឃាត់ លើកលែងតែរដ្ឋាភិបាលរបស់ប្រទេសដែលនាំចូល បញ្ជាក់លើប័ណ្ណនាំចូលដែលធ្វើឡើងដោយបុគ្គល ឬទីតាំងដែលបានដាក់ពាក្យសុំសិទ្ធិនាំចេញដែលខ្លួនបានឯកភាពរោយមានការនាំចូល ដោយមានបំណងដាក់ក្នុងទីតាំងផ្ទុកទំនិញជួលនោះ ។ ក្នុង

ករណីនេះ សិទ្ធិអនុញ្ញាតនៃការនាំចេញ ត្រូវកំណត់ថា ឥវ៉ាន់ទាំងនោះ ត្រូវនាំចេញស៊ាប់គោលបំណងនេះ ។ ការដកឥវ៉ាន់ណាមួយចេញពីទីតាំងនេះ ត្រូវធ្វើឡើងដោយមានការអនុញ្ញាតពីអាជ្ញាធរដែលមានដែនអំណាចលើទីតាំងផ្តុកទំនិញនោះ និងក្នុងករណីការបញ្ជូនទៅគោលដៅបរទេស ត្រូវចាត់ទុកថាជាការនាំចេញថ្មីមួយក្នុងអត្ថន័យនៃអនុសញ្ញានេះ ។

១០. ការដឹកជញ្ជូនគ្រឿងឈ្មោនចូល ឬចេញពីដែនដីរបស់ភាគីមួយដែលមិនមានអមដោយសិទ្ធិអនុញ្ញាតនាំចេញ ត្រូវឃាត់ទុកដោយអាជ្ញាធរមានសមត្ថកិច្ច ។

១១. ភាគីមួយ មិនត្រូវអនុញ្ញាតអោយធ្វើបច្ចុនថ្នាំឈ្មោនទៅប្រទេសមួយផ្សេងទៀត ដោយឆ្លងកាត់ដែនដីរបស់ខ្លួនទោះបីជាទំនិញទាំងនោះ ត្រូវបានយកចេញពីមធ្យោបាយដឹកជញ្ជូនដែលកំពុងដំណើរកំដោយលើកលែងតែមានឯកសារចម្លងមួយច្បាប់នៃសិទ្ធិអនុញ្ញាតអោយនាំចេញនូវទំនិញទាំងនេះ ដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីនោះ ។

១២. អាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេស ឬ ដែនដីណាមួយដែលតាមរយៈនោះទំនិញជាគ្រឿងឈ្មោនត្រូវបានអនុញ្ញាតអោយឆ្លងកាត់ ត្រូវចាត់វិធានការសមស្រប ដើម្បីបង្ការការបែកខ្ញែកទំនិញទៅគោលដៅណាមួយផ្សេងទៀត ក្រៅពីគោលដៅដែលបានកំណត់ក្នុងឯកសារអមលើសិទ្ធិអនុញ្ញាតនាំចេញ លើកលែងតែរដ្ឋាភិបាលរបស់រដ្ឋ ឬដែនដីដែលមានទំនិញនោះឆ្លងកាត់ អនុញ្ញាតអោយមានការដាក់ក្នុងទិសដៅផ្សេង ។ រដ្ឋាភិបាលនៃប្រទេស ឬដែនដីឆ្លងកាត់ ត្រូវចាត់ទុកការបង្វែរទៅទិសដៅផ្សេង ដូចជាការនាំចេញតាមប្រទេស ឬដែនដីឆ្លងកាត់ទៅប្រទេស ឬដែនដីផ្សេងទៀតដែលជាគោលដៅថ្មី ។ ប្រសិនបើការបង្វែរទិសដៅត្រូវបានទទួលការអនុញ្ញាត បទប្បញ្ញត្តិនៃកថាខ័ណ្ឌ ៧ (ក) និង (ខ) ក៏ត្រូវអនុវត្តន៍រវាងប្រទេស ឬដែនដីដែលឆ្លងកាត់ និងប្រទេស ឬដែនដីដែលជាចំនុចចាប់ផ្តើមនៃការបញ្ជូនអ៊ីវ៉ាន់ ។

១៣. ខណៈពេលឆ្លងកាត់ ឬខណៈពេលដាក់ដកល់ក្នុងឃ្លាំង គ្មានទំនិញថ្នាំឈ្មោនណាមួយ ដែលត្រូវស្ថិតនៅក្រោមដំណើរ អាចផ្លាស់ប្តូរសភាពដើមនៃថ្នាំឈ្មោននោះទេ ។ កញ្ចប់រុំត្រូវរក្សាទុកនៅដដែលដោយមិនមានការកែប្រែប្រសិនបើមិនមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ។

១៤. បញ្ញត្តិនៃកថាខ័ណ្ឌ ១១ ដល់ ១៣ ដែលទាក់ទងនឹងច្រកផ្លូវថ្នាំឈ្មោនតាមរយៈដែនដីរបស់ភាគី មួយមិនត្រូវអនុវត្តន៍ចំពោះទំនិញដូចបានលើកឡើង ដែលដឹកជញ្ជូនដោយយន្តហោះ ហើយមិនចុះចតក្នុង ប្រទេស ឬដែនដីឆ្លងកាត់នោះ ។ ប្រសិនបើយន្តហោះចុះចតក្នុងប្រទេស ឬដែនដីណាមួយ បទបញ្ញត្តិទាំងនោះត្រូវយកទៅអនុវត្តទៅតាមកាលៈទេសៈតំរូវ ។

១៥. បញ្ហត្តិនៃមាត្រានេះ មិនរើសអើងចំពោះបញ្ហត្តិដទៃទៀតរបស់កិច្ចព្រមព្រៀងអន្តរជាតិ ដែលកំរិតពីការត្រួតពិនិត្យដែលអាចអនុវត្តន៍បានដោយភាគីណាមួយចំពោះថ្នាំញៀនដែលកំពុងឆ្លងកាត់ ។

១៦. មិនមានអ្វីក្នុងមាត្រានេះក្រៅពីកថាខ័ណ្ឌ ១ (ក) និង ២ ត្រូវយកទៅអនុវត្តន៍ក្នុងករណីនៃការរៀបចំតារាង III ឡើយ ។

មាត្រា ៣២

បទប្បញ្ញត្តិពិសេសទាក់ទងនឹងការដុតថ្នាំញៀនក្នុងប្រអប់ឧបករណ៍សង្គ្រោះបន្ទាន់ របស់កប៉ាល់ ឬយន្តហោះដែលពាក់ព័ន្ធនឹងការធ្វើចរាចរជាអន្តរជាតិ

១. ការដឹកជញ្ជូនជាអន្តរជាតិដោយកប៉ាល់ ឬដោយយន្តហោះនូវចំនួនថ្នាំញៀនមួយដែលបានកំណត់តាមសេចក្តីត្រូវការជួយសង្គ្រោះបន្ទាន់នៅពេលធ្វើដំណើរ ឬករណីសង្គ្រោះបន្ទាន់មិនត្រូវចាត់ទុកថាជាការនាំចូល ការនាំចេញ ឬការឆ្លងកាត់តាមប្រទេសក្នុងអត្ថន័យនៃអនុសញ្ញានេះទេ ។

២. ប្រទេសដែលបានចុះបញ្ជី ត្រូវចាត់វិធានការអោយបានសមស្រប ដើម្បីបង្ការការប្រើប្រាស់មិនត្រឹមត្រូវនូវថ្នាំញៀន ដូចមានចែងក្នុងកថាខ័ណ្ឌ ១ ឬការបង្ខែរបស់គេក្នុងគោលដៅខុសច្បាប់ ។ ដោយមានការប្រឹក្សាជាមួយនឹងអង្គការអន្តរជាតិសមស្រប គណៈកម្មការ ត្រូវផ្តល់អនុសាសន៍ចំពោះការការពារទាំងនោះ ។

៣. ថ្នាំញៀនដែលដឹកជញ្ជូនដោយកប៉ាល់ ឬ យន្តហោះស្របតាមកថាខ័ណ្ឌ ១ ត្រូវធ្វើឡើងដោយស្របនឹងច្បាប់ បទបញ្ជា សេចក្តីអនុញ្ញាត និងអាជ្ញាប័ណ្ណរបស់ប្រទេសដែលបានចុះបញ្ជី ដោយមិនរើសអើងចំពោះសិទ្ធិណាមួយរបស់អាជ្ញាធរមានសមត្ថកិច្ចនៅក្នុងតំបន់ក្នុងការអនុវត្តន៍ការឆែក ពិនិត្យ អធិការកិច្ច និងវិធានការត្រួតពិនិត្យផ្សេងៗទៀតលើ កប៉ាល់ ឬលើយន្តហោះ។ ការប្រើប្រាស់ថ្នាំញៀននៅក្នុងករណីសង្គ្រោះបន្ទាន់ មិនត្រូវចាត់ទុកថាជាការរំលោភលើតំរូវការនៃមាត្រា ៣០ កថាខ័ណ្ឌ ២(ខ) ឡើយ ។

មាត្រា ៣៣

ការកាន់កាប់ថ្នាំញៀន

ភាគីទាំងអស់មិនត្រូវអនុញ្ញាតអោយមានថ្នាំញៀនជាកម្មសិទ្ធិផ្ទាល់ខ្លួនទេ លើកលែងតែបានក្រោមរំណាចច្បាប់ ។

មាត្រា ៣៤

វិធានការត្រួតពិនិត្យមើល និងអធិការកិច្ច

ភាគីទាំងអស់ត្រូវតំរូវថា :

ក- ជនទាំងឡាយដែលមានអាជ្ញាប័ណ្ណ ដូចដែលបានផ្តល់ជូន ដោយអនុលោមទៅតាមអនុសញ្ញានេះ ឬ ដែលមានតួនាទីត្រួតត្រាមើល ឬគ្រប់គ្រងក្នុងសហគ្រាសរបស់រដ្ឋដែលបានបង្កើតឡើង ដោយអនុលោមទៅតាមអនុសញ្ញានេះ ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីប្រតិបត្តិបទបញ្ជត្តិច្បាប់ និងបទបញ្ជត្តិទាំងនោះ អោយមានប្រសិទ្ធភាព និងប្រកបដោយភក្តី ដូចដែលបានអនុម័តដោយអនុលោមទៅតាមនោះហើយ.

ខ- អាជ្ញាធររដ្ឋាភិបាល អ្នកផលិត អ្នកជំនួញ អ្នកវិទ្យាសាស្ត្រ គ្រឹះស្ថានវិទ្យាសាស្ត្រ និងមន្ទីរពេទ្យ រក្សាទុកឯកសារទាំងនោះ ដែលនឹងបង្ហាញពីថ្នាំញៀននីមួយៗដែលបានផលិត និងបរិមាណថ្នាំញៀនដែលទទួលបានមួយមុខៗ ព្រមទាំងកាកសំណល់របស់ថ្នាំញៀន ។ របាយការណ៍ទាំងនោះ ត្រូវរក្សាទុករៀងៗខ្លួនមិនអោយតិចជាងរយៈពេល២ឆ្នាំឡើយ។ គេប្រើប្រាស់ស្បៀវភៅកត់ត្រាបញ្ជត្តិជាផ្លូវការ (មាត្រា ៣០ កថាខ័ណ្ឌ ២ (ខ)) ស្បៀវភៅទាំងនោះ រួមបញ្ចូលទាំងគល់បញ្ជី ត្រូវរក្សាទុកផងដែរមិនអោយតិចជាងរយៈពេល ២ឆ្នាំ ។

មាត្រា ៣៥

សកម្មភាពប្រឆាំងនឹងការចរាចរខុសច្បាប់

ដោយមានការគោរពចំពោះប្រព័ន្ធរដ្ឋបាល ច្បាប់ និងរដ្ឋធម្មនុញ្ញ ភាគីទាំងអស់ត្រូវ :

ក- រៀបចំកិច្ចសំរបសំរួលថ្នាក់ជាតិមួយ សំរាប់កិច្ចសហប្រតិបត្តិការ ក្នុងសកម្មភាពទប់ស្កាត់ និងបង្ក្រាប ប្រឆាំងនឹងការចរាចខុសច្បាប់ ដើម្បីឈានទៅដល់ការបញ្ចប់បញ្ហានេះ ពួកគេអាចជ្រើសភ្នាក់ងារសមស្របមួយដ៏មានសារៈប្រយោជន៍អោយទទួលខុសត្រូវចំពោះកិច្ចសហប្រតិបត្តិការនោះ ។

ខ- ជួយគ្នាទៅវិញទៅមកក្នុងយុទ្ធនាការប្រឆាំងនឹងការជួញដូរគ្រឿងញៀនខុសច្បាប់ ។

គ- សហការយ៉ាងជិតស្និទ្ធជាមួយគ្នាទៅវិញទៅមក និង ជាមួយអង្គការអន្តរជាតិដែលមានសម្ថកិច្ចដែលជាសមាជិកដោយមានគោលបំណងថែរក្សានូវយុទ្ធនាការសំរបសំរួលប្រឆាំង នឹងការជួញដូរខុសច្បាប់ ។

ឃ- ធានាថា កិច្ចសហប្រតិបត្តិការអន្តរជាតិ រវាងភ្នាក់ងារសមស្រប ត្រូវបានធ្វើឡើងដោយរួសរាន់ហើយ.

ង- ធានាថា កន្លែងដែលគេបញ្ជូនលិខិតស្នាមផ្លូវច្បាប់ជាអន្តរជាតិក្នុងគោលបំណងចោទប្រកាន់ ការបញ្ជូន ត្រូវធ្វើអោយមានប្រសិទ្ធភាពយ៉ាងរួសរាន់ ទៅអង្គការដែលជ្រើសរើសដោយភាគីទាំងអស់ តំរូវការនេះ មិនត្រូវលំអៀងដល់សិទ្ធិរបស់ភាគីណាមួយ ចំពោះតំរូវការដែលលិខិតស្នាមផ្លូវច្បាប់នោះ ត្រូវបានបញ្ជូនទៅអោយខ្លួនតាមរយៈអង្គទូតឡើយ ។

ច- ប្រសិនបើចាត់ទុកថាសមស្រប ត្រូវផ្តល់ទៅអោយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ និងគណៈកម្មាការ តាមរយៈអគ្គលេខាធិការ ក្រៅពីពត៌មានដែលតំរូវអោយមានតាមរយៈមាត្រា ១៨ ពត៌មានដែលទាក់ទងទៅនឹងសកម្មភាពគ្រឿងញៀនខុសច្បាប់នៅក្នុងព្រំដែនរបស់គេ ដោយរួមបញ្ចូលទាំងពត៌មាន ស្តីពីការដាំ ការផលិត ការធ្វើ និងការប្រើប្រាស់ និងការចរាចរគ្រឿងញៀនខុសច្បាប់ផ្ទៀង

ឆ- ផ្តល់ជូននូវពត៌មានដោយយោងទៅតាមកថាខ័ណ្ឌពីមុន តាមដែលអាចធ្វើទៅបាននៅក្នុងលក្ខណៈបែបនោះ ហើយតាមរយៈកាលបរិច្ឆេទនោះ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ អាចស្នើសុំ ប្រសិនបើត្រូវបានស្នើសុំដោយភាគីមួយ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិអាចផ្តល់យោបល់របស់ខ្លួនទៅអោយ ក្នុងការផ្តល់ពត៌មាន និង ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយសកម្មភាពគ្រឿងញៀនខុសច្បាប់នៅតាមព្រំដែនរបស់ភាគីនោះ ។

មាត្រា ៣៦
បទប្បញ្ញត្តិព្រហ្មទណ្ឌ

១ (ក) ចំពោះការកំរិតដោយរដ្ឋធម្មនុញ្ញរបស់ខ្លួន ភាគីនីមួយៗ ត្រូវអនុម័តវិធានការទាំងអស់នោះ ដែលនឹងធានាថា ការដាំដុះ ការផលិត ការធ្វើ ចំរាញ់ ការរៀបចំ ការកាន់កាប់ ការផ្តល់អោយ ការផ្តល់អោយលក់ ការបែងចែក ការទិញ ការលក់ ការប្រគល់អោយទោះតាមមធ្យោបាយណាក៏ដោយ ការធ្វើបរជើងសារ ការបញ្ជូន ការបញ្ជូនដោយឆ្លងកាត់ ការដឹកជញ្ជូន ការនាំចេញ និង ការនាំចូលនូវគ្រឿងញៀនទាំងអស់ដែលផ្ទុយទៅនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះ ហើយសកម្មភាពដទៃទៀតណាក៏ដោយ ដែលជាទស្សនៈរបស់ភាគីណាមួយ អាចផ្ទុយនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះ នឹងជាបទល្មើស ដែលអាចត្រូវផ្តន្ទាទោសនៅពេលណាបាន

ប្រព្រឹត្តដោយចេតនាហើយបទល្មើសដ៏ធ្ងន់ធ្ងរនោះ នឹងអាចមានការផ្តន្ទាទោសអោយបានត្រប់ត្រាន់ជាពិសេស តាមរយៈការដាក់គុក ឬការផ្តន្ទាទោសផ្សេងទៀត ដោយដកហូតសិទ្ធិសេរីភាព ។

ខ. ទោះបីជាមានអនុកថាខ័ណ្ឌមុន១ក៏ដោយ នៅពេលដែលអ្នកប្រើប្រាស់គ្រឿងញៀនបានប្រព្រឹត្តបទល្មើសទាំងនោះ ទាំងជាប់ពីសកាត់អោយជាប់ទោស ឬទាំងការដាក់ទណ្ឌកម្ម ឬ ក្រៅពីការកាត់អោយជាប់ទោស ឬការដាក់ទណ្ឌកម្ម ភាគីទាំងឡាយ អាចចែងថា អ្នកប្រើប់ពានគ្រឿងញៀនទាំងនោះ នឹងត្រូវទទួលរ៉ាប់រងវិធានការព្យាបាល ការអប់រំ ការថែទាំ ការស្តារនីតិសម្បទា និង ការធ្វើសមាហរណកម្មចូលទៅក្នុងសង្គមជាតិវិញ ស្របតាមកថាខ័ណ្ឌទី ១ នៃមាត្រា ៣៨ ។

២- ចំពោះការកំរិតដោយរដ្ឋធម្មនុញ្ញរបស់ភាគីមួយ ប្រព័ន្ធច្បាប់ និងច្បាប់ក្នុងស្រុករបស់ខ្លួន ត្រូវមាន :

ក- (i) បទល្មើសនីមួយ១ដែលបានរៀបរាប់នៅក្នុងកថាខ័ណ្ឌទី១ បើបានប្រព្រឹត្តនៅក្នុងប្រទេសផ្សេង១ ត្នា ត្រូវចាត់ទុកជាបទល្មើសដោយឡែកពីគ្នា ។

(ii) ការចូលរួមដោយចេតនា ការរួមគំនិតដើម្បីប្រព្រឹត្ត ការប៉ុនប៉ងប្រព្រឹត្ត និងទង្វើណាមួយនៃបទល្មើសបែបហ្នឹង ហើយនិងអំពើដែលរៀបចំបំរុងទុក និងប្រតិបត្តិការហិរញ្ញវត្ថុ ជាប់ពាក់ព័ន្ធនឹងបទល្មើសដែលមានចែងក្នុងមាត្រានេះ ត្រូវជាបទល្មើសដែលអាចផ្តន្ទាទោស ដូចដែលបានចែងក្នុងកថាខ័ណ្ឌ១ ។

(iii) ការកាត់ទោសនៅឯបរទេសចំពោះបទល្មើសបែបហ្នឹង ត្រូវយកមកគិតបញ្ចូនជាភាពមិនរាងចាលហើយ

(iv) ចំពោះបទល្មើសធ្ងន់ធ្ងរដែលបានប្រព្រឹត្តឡើងទាំងជាតិ និងជនបរទេសនោះ ត្រូវបានចោទប្រកាន់ដោយភាគីដែលបទល្មើសបានប្រព្រឹត្តឡើងក្នុងទឹកដីនោះ ឬដោយភាគីដែលជនល្មើស ត្រូវបានគេរកឃើញនៅក្នុងទឹកដីនោះ ប្រសិនបើបក្សាប័នមិនអាចទទួលយកបាន ដោយអនុលោមទៅតាមច្បាប់របស់ភាគីដែលបានអនុវត្ត ហើយប្រសិនបើជនល្មើសមិនត្រូវបានចោទប្រកាន់ និងផ្តល់ការវិនិច្ឆ័យទោសរួចជាស្រេច ។

ខ- (i)បទល្មើសនីមួយ១ក្នុងចំណោមបទល្មើសដូចបានរៀបរាប់ក្នុងកថាខ័ណ្ឌទី ១ និងទី២ (ក) (ii) នៃមាត្រានេះ ត្រូវចាត់ទុកថាបានរួមបញ្ចូលនូវបទល្មើសបក្សាប័ន នៅក្នុងសន្ធិសញ្ញាបក្សាប័នណាមួយដែលមានរវាងភាគីទាំងសង្ខាង ។ ភាគីទាំងឡាយទទួលរ៉ាប់រង ដើម្បីបញ្ចូលបទល្មើសទាំងនោះដូចជាបទល្មើសបក្សាប័ននូវរាល់សន្ធិសញ្ញាបក្សាប័ន ដែលត្រូវបានរួមបញ្ចូលរវាងភាគីទាំងនោះ ។

(ii) ប្រសិនបើភាគីមួយ ដែលធ្វើបត្យាប័នប្រកបដោយលក្ខខណ្ឌ ស្តីពីការមានសិទ្ធិសញ្ញាមួយ ដែលសិទ្ធិសញ្ញានោះ ទទួលបានសំណើមួយសំរាប់ការធ្វើបត្យាប័នពីភាគីផ្សេងទៀត ជាមួយនោះ ភាគីនោះមិនមានសិទ្ធិសញ្ញាបត្យាប័នតាមគំនិតរបស់គេ គេអាចចាត់ទុកអនុសញ្ញានេះថាជាមូលដ្ឋានស្របច្បាប់សំរាប់បត្យាប័ន ចំពោះបទល្មើសដូចបានរៀបរាប់ក្នុងកថាខ័ណ្ឌទី ១ និងទី ២ (ក) (ii) នៃមាត្រានេះ ។ បត្យាប័ន ត្រូវតែជាកម្មវត្ថុនៃលក្ខខណ្ឌផ្សេងៗទៀតដែលមានចែងដោយច្បាប់របស់ភាគីទទួលសំណើ ។

(iii) ភាគីទាំងឡាយ ដែលមិនធ្វើបត្យាប័នប្រកបដោយលក្ខខណ្ឌ ទៅលើអត្ថិភាពនៃសិទ្ធិសញ្ញាមួយ ត្រូវទទួលស្គាល់បទល្មើសដូចបានរៀបរាប់នៅក្នុងកថាខណ្ឌទី ១ និងទី ២ (ក) (ii) នៃមាត្រានេះ ថាជាបទល្មើសដែលមានបត្យាប័នរវាងភាគីទាំងពីរ ចំពោះលក្ខខណ្ឌដូចមានចែង ដោយច្បាប់របស់ភាគីទទួលសំណើ ។

(iv) បត្យាប័ន នឹងត្រូវបានផ្តល់អោយ ដោយអនុលោមទៅតាមច្បាប់របស់ភាគី ដែលភាគីនោះបានអនុវត្ត ហើយទោះបីជាមានអនុកថាខណ្ឌ (ខ) (i) (ii) និង (iii) នៃកថាខណ្ឌនេះក៏ដោយ ភាគីនោះត្រូវមានសិទ្ធិបដិសេធមិនផ្តល់បត្យាប័ន ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចចាត់ទុកថាបទល្មើសនោះគឺមិនមានលក្ខណៈធ្ងន់ធ្ងរ ។

៣. បទប្បញ្ញត្តិនៃមាត្រានេះ ត្រូវស្ថិតនៅក្រោមបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌរបស់ភាគីដែលពាក់ព័ន្ធស្តីពីបញ្ហាយុត្តាធិការ ។

៤. មិនមានអ្វីនៅក្នុងមាត្រានេះ ត្រូវបំភ្លេចដល់គោលការណ៍ថា បទល្មើសដែលបានយោង ត្រូវបានកំណត់និយមន័យ ចោទប្រកាន់ និងផ្តន្ទាទោសស្របតាមច្បាប់ក្នុងស្រុករបស់ភាគីទេ ។

មាត្រា ៣៧

ការចាប់យក និង ការរឹបអូស

ត្រឿងញៀន សារធាតុ និង ឧបករណ៍ណាក៏ដោយដែលប្រើ ឬមានបំណងថាយកទៅប្រើដើម្បីប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៣៦ ត្រូវធ្វើការចាប់យក និង រឹបអូស ។

មាត្រា ៣៨

វិធានការប្រឆាំងនឹងការប្រើប្រាស់ត្រឿងញៀន

១. ភាគីត្រូវផ្តល់ការយកចិត្តទុកដាក់ពិសេសដល់ និងចាត់វិធានការ ដែលអាចធ្វើទៅតាមទាំងអស់ សំរាប់ការទប់ស្កាត់ការប្រើប់ពានគ្រឿងញៀន និង សំរាប់ការកំណត់អត្តសញ្ញាណដំបូង ការព្យាបាល ការអប់រំ ការថែទាំ ការស្តារនីតិសមប្បទា ការធ្វើសមាហរណកម្មអ្នកដែលពាក់ព័ន្ធទាំងនោះអោយចូលទៅក្នុងសង្គមវិញ ហើយ និងសំរបសំរួលកិច្ចខិតខំប្រឹងប្រែងរបស់គេដើម្បីបញ្ចប់បញ្ហាទាំងនេះ ។

២. ភាគីត្រូវបង្កើនតាមលទ្ធភាពដែលអាចធ្វើទៅបាន ចំពោះការបណ្តុះបណ្តាលបុគ្គលិកផ្នែកការព្យាបាល ការថែទាំ ការស្តារនីតិសម្បទា និង ការធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀនអោយចូលទៅក្នុងសង្គមជាតិវិញ ។

៣. ភាគីត្រូវចាត់វិធានការតាមលទ្ធភាពដែលអាចធ្វើទៅតាម ដើម្បីជួយបុគ្គលដែលការងាររបស់ពួកគេត្រូវការឱ្យមានដូច្នោះ ដើម្បីទទួលបានការយល់ដឹងពីបញ្ហានៃការប្រើប់ពានគ្រឿងញៀន និងការទប់ស្កាត់របស់ខ្លួន ហើយនឹងបង្កើនអោយមានការយល់ដឹងក្នុងចំណោមប្រជាជនទូទៅ ប្រសិនបើមានគ្រោះថ្នាក់ដែលការប្រើប់ពានគ្រឿងញៀន នឹងរាលដាល ។

មាត្រា ៣៨ ស្ទួន

កិច្ចព្រមព្រៀង ស្តីពីមជ្ឈមណ្ឌលតំបន់

ប្រសិនបើភាគីមួយចាត់ទុកថា វាគឺជាបំណងប្រាថ្នា ដែលជាផ្នែកមួយនៃសកម្មភាពរបស់ខ្លួន ប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់ ការមានចំពោះប្រព័ន្ធរដ្ឋបាល ច្បាប់ និងវដ្តធម្មនុញ្ញរបស់ខ្លួន ហើយប្រសិនបើគេប្រាថ្នាដូច្នោះ ជាមួយយោបល់បច្ចេកទេសរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ឬភ្នាក់ងារពិសេស ក្នុងការពិគ្រោះយោបល់ជាមួយភាគីដែលមានប្រយោជន៍ដទៃទៀត នៅក្នុងតំបន់ គេនឹងជំរុញអោយមានការបង្កើតនូវកិច្ចព្រមព្រៀង ដែលសង្ឃឹមថានឹងមានការអភិវឌ្ឍន៍សំរាប់ការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ និងការអប់រំ ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងបញ្ហាដែលចេញមកពីការប្រើប់ពាន និងការចរាចរគ្រឿងញៀនខុសច្បាប់ ។

មាត្រា ៣៩

ការអនុវត្តនីវិធានការត្រួតពិនិត្យថ្នាក់ជាតិ អោយតឹងរឹង ជាងវិធានការដែលបានកំណត់ក្នុងអនុសញ្ញានេះ

ទោះបីជាមានអ្វីៗដែលបានផ្តុំកក្នុងអនុសញ្ញានេះ ភាគីមិនត្រូវចាត់ទុក ឬច្រានចោលការអនុម័ត វិធានការត្រួតពិនិត្យតឹងរឹងជាងវិធានការដែលមានចែងក្នុងអនុសញ្ញានេះ ហើយជាពិសេសទាក់ទងនឹងការរៀបចំតារាង III ឬគ្រឿងញៀនក្នុងតារាង II ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ ឬវិធានការនៃការត្រួតពិនិត្យទាំងឡាយណាដែលអាចអនុវត្តបានចំពោះគ្រឿងញៀនក្នុងតារាង I ដោយតាមគំនិតរបស់ខ្លួន គឺមានសារៈសំខាន់ ឬ ចង់បានសំរាប់ការការពារសុខភាព ឬសុខុមាលភាពសាធារណៈ ។

មាត្រា ៥០[៣]

ភាសារបស់អនុសញ្ញា និង នីតិវិធីក្នុងការចុះហត្ថលេខា ការធ្វើសច្ចាប័ន និងការទទួលយក

១. អត្ថបទជាភាសាចិន អង់គ្លេស បារាំង រុស្ស៊ី និងភាសាអេស្ប៉ាញ ដែលមានក្នុងអនុសញ្ញានេះ គឺមានតំលៃដើមស្មើៗគ្នា ហើយអនុសញ្ញានេះ នឹងត្រូវបើកចំហរអោយចុះហត្ថលេខារហូតដល់ថ្ងៃ ១ ខែ សីហា ១៩៦១ ក្នុងនាមជាសមាជិករបស់អង្គការសហប្រជាជាតិ រដ្ឋដែលមិនមែនជាសមាជិកដែលជាភាគីមួយចំពោះលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ ឬសមាជិករបស់ភ្នាក់ងារជំនាញរបស់អង្គការសហប្រជាជាតិ និងរដ្ឋផ្សេងៗទៀតដែលក្រុមប្រឹក្សាអាចអញ្ជើញអោយធ្វើជាភាគី ។

២. អនុសញ្ញានេះ ត្រូវដាក់អោយធ្វើសច្ចាប័ន ។ លិខិតតុបករណ៍នៃការធ្វើសច្ចាប័ន ត្រូវដាក់ជូនលទុកនៅអគ្គលេខាធិការ ។

---

[៣] កំណាត់សំគាល់ដោយលេខាធិការដ្ឋាន : ដូចតទៅនេះ កថាខ័ណ្ឌពីរត្រូវបានកយកចេញពីកំណាត់សំគាល់សេចក្តីផ្តើមចំពោះអត្ថបទនៃអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ ដូចបានធ្វើវិសោធនកម្មដោយពិធីសារ ឆ្នាំ ១៩៧២ ដែលបានកែប្រែអនុសញ្ញាទោលស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ ដែល បានរៀបចំឡើងដោយអគ្គលេខាធិការនៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៧៥ ដោយអនុលោមតាមមាត្រា ២២ នៃពិធីសារ ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៧២ :

[*] ពិធីសារដែលកែប្រែអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ (ហៅថា ពិធីសារឆ្នាំ ១៩៧២) ចូលជាធរមាននៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៧៥ ដោយអនុលោមតាមកថាខ័ណ្ឌ ១ នៃមាត្រា ៨ របស់ខ្លួន ។ ចំពោះរដ្ឋណាមួយដែលជាភាគីនៃអនុសញ្ញានោះរួចជាស្រេច ហើយដាក់ទុកនៅអគ្គលេខាធិការ បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់ទុកលិខិតតុបករណ៍នៃការអោយសច្ចាប័ន ឬការចូលរួមរយៈពេល ៤០ ថ្ងៃ លិខិតតុបករណ៍ នៃការផ្តល់សច្ចាប័ន ឬ ការចូលរួមចំពោះពិធីសារ ឆ្នាំ ១៩៧២ ក្រោយមកនឹងចូលជាធរមានក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីការដាក់ផ្តល់ទុកនូវលិខិតតុបករណ៍របស់ខ្លួន ដោយរដ្ឋនោះ (សូមបើលមាត្រា ១៧ និង ១៨ នៃពិធីសារ ឆ្នាំ ១៩៧២) ។

[*] រដ្ឋណាមួយដែលក្លាយទៅជាភាគីនៃអនុសញ្ញាទោល បន្ទាប់ពីការចូលជាធរមាននៃពិធីសារឆ្នាំ ១៩៧២ ដែលមានកំហុសចំពោះការសំដែងឆ្លងទាស់ផ្សេងគ្នាដោយរដ្ឋនោះ នឹង ក) ត្រូវចាត់ទុកថាជាភាគីមួយចំពោះអនុសញ្ញាទោលដូចដែលបានធ្វើវិសោធនកម្ម និង ខ) ត្រូវបានចាត់ទុកថាជាភាគីមួយចំពោះអនុសញ្ញាទោលដែលមិនទាន់បានកែប្រែ ទាក់ទងទៅនឹងភាគីមួយផ្សេងទៀតចំពោះអនុសញ្ញានោះដែលមិនត្រូវបានចងភ្ជាប់ដោយពិធីសារ ឆ្នាំ ១៩៧២ (សូមអើលពិធីសារ ឆ្នាំ ១៩៧២) ។

៣. អនុសញ្ញានេះត្រូវបើកចំហ បន្ទាប់ពីថ្ងៃទី ១ សីហា ១៩៦១ សំរាប់ការចូលរួមដោយរដ្ឋដែលមានចែងក្នុងកថាខ័ណ្ឌ ១ ។ លិខិតតុបករណ៍នៃការចូលរួម ត្រូវដាក់ដំកល់ទុកនៅអគ្គលេខាធិការ ។

មាត្រា ៤១[៤]

ការចូលជាធរមាន

១. អនុសញ្ញានេះ នឹងចូលជាធរមាន ៣០ ថ្ងៃ ក្រោយពីកាលបរិច្ឆេទនៃលិខិតតុបករណ៍សំរាប់ការផ្តល់សច្ចាប័ន ឬការទទួលយកទី ៤០ ត្រូវបានដាក់ដំកល់ទុក ស្របទៅតាមមាត្រា ៤០ ។

២. ចំពោះរដ្ឋផ្សេងៗទៀតដែលដាក់ដំកល់លិខិតតុបករណ៍អំពីការធ្វើសច្ចាប័ន ឬការទទួលយកក្រោយកាលបរិច្ឆេទនៃការដាក់ដំកល់លិខិតតុបករណ៍ទី៤០ ដែលបានលើកឡើង អនុសញ្ញានេះ ត្រូវចូលជាធរមាននៅ ៣០ថ្ងៃ ក្រោយពីការដាក់ដំកល់របស់រដ្ឋនោះនូវលិខិតតុបករណ៍នៃការធ្វើសច្ចាប័ន ឬការទទួលយករបស់ខ្លួន ។

មាត្រា ៤២

ដែនអនុវត្តន៍/ឃុត្តាធិការ

អនុសញ្ញានេះ ត្រូវអនុវត្តចំពោះដែនដីទាំងអស់ក្នុងទំនាក់ទំនងអន្តរជាតិដែលភាគីណាមួយទទួលខុសត្រូវលើកលែងតែក្នុងករណីដែលតំរូវអោយមានការសុំការឯកភាពជាមុនពីដែនដីនោះដោយធម្មនុញ្ញរបស់ភាគី ឬរបស់ដែនដីដែលពាក់ពន្ធ័ ឬតំរូវដោយគយ ។ ក្នុងករណីនេះ ភាគីត្រូវខិតខំ ដើម្បីបានាអោយបាននូវការឯកភាពដែលត្រូវការអំពីដែនដី ក្នុងរយៈពេលមួយដ៏ខ្លីតាមដែលអាចធ្វើទៅបាន និងនៅពេលទទួលបានការឯកភាពទាំងនោះ ភាគីត្រូវជូនដំណឹងដល់អគ្គលេខាធិការ ។ អនុសញ្ញានេះ ត្រូវអនុវត្តន៍ចំពោះដែនដីដែលមានឈ្មោះក្នុងសេចក្តីជូនដំណឹងនោះ ចាប់ពីកាលបរិច្ឆេទទទួលរបស់អគ្គលេខាធិការ ។ ក្នុងករណីដែលមិនបានទទួលការឯកភាពពីដែនដី ភាគីពាក់ពន្ធ័ ត្រូវប្រកាសពីទីតាំងដែលត្រូវអនុវត្តន៍អនុសញ្ញានេះនៅពេលចុះហត្ថលេខា ការធ្វើសច្ចាប័ន ឬ ការទទួលយក ។

មាត្រា ៤៣

ដែនដីសំរាប់គោលបំណងនៃមាត្រា ១៩, ២០, ២១, និង ៣១

---

[៤] សូមមើលកំណាត់ចំណាំ ៣ ខាងលើ (See foot-note 3 above) ។

១. ភាគីណាក៏ដោយ អាចជូនដំណឹងដល់អគ្គលេខាធិការថា ដើម្បីគោលបំណងនៃមាត្រា ១៩. ២០. ២១. និង ៣១ ដែនដីមួយក្នុងចំណោមដែនដីរបស់ខ្លួន ត្រូវបែងចែកជាពីរ ឬ ច្រើន ឬក៏អាចថា ដែនដីរបស់ខ្លួន ពីរ ឬច្រើន ត្រូវដាក់បញ្ចូលអោយទៅតែមួយ ។

២. ភាគីពីរ ឬច្រើន អាចជូនដំណឹងដល់អគ្គលេខាធិការថា ជាលទ្ធផលនៃការបង្កើតសហគមគយមួយ រវាងពួកគេ ភាគីទាំងនោះ គឺជាដែនដីតែមួយសំរាប់គោលបំណងនៃមាត្រា ១៩. ២០. ២១. និង ៣១ ។

៣. រាល់ការជូនដំណឹងតាមកថាខ័ណ្ឌ ១ ឬ ២ ខាងលើ ត្រូវមានប្រសិទ្ធភាពចាប់ពី ១ មករា នៃឆ្នាំបន្ទាប់ ដែលក្នុងឆ្នាំនោះ សេចក្តីជូនដំណឹង ត្រូវបានធ្វើឡើង ។

មាត្រា ៤៤

ការបញ្ចប់សន្ធិសញ្ញាអន្តរជាតិមុនៗ

១. ក្រោយពីចូលជាធរមានរវាងភាគីក្នុងអនុសញ្ញានេះ បទប្បញ្ញត្តិនៃអនុសញ្ញានេះត្រូវបញ្ចប់ និងជំនួសដោយបញ្ញត្តិនៃសន្ធិសញ្ញាខាងក្រោម :

(ក) អនុសញ្ញាអាភៀនអន្តរជាតិបានចុះហត្ថលេខានៅទីក្រុងឡាអេ ថ្ងៃទី ២៣ ខែមករា ១៩១២.

(ខ) កិច្ចព្រមព្រៀងទាក់ទងនឹងការផលិត ការធ្វើជំនួញក្នុងស្រុក និងការប្រើប្រាស់អាភៀនផ្សំ បានចុះហត្ថលេខានៅទីក្រុង ហ្សឺណែវ នៅថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ១៩២៥.

(គ) អនុសញ្ញាអាភៀនអន្តរជាតិ បានចុះហត្ថលេខានៅទីក្រុង ហ្សឺណែវ ថ្ងៃទី ១៩ កុម្ភៈ ១៩២៥

(ឃ) អនុសញ្ញាសំរាប់ការកំរិតការផលិត និង ការបទញ្ញើការចែកចាយគ្រឿងញៀន បានចុះហត្ថលេខានៅទីក្រុង ហ្សឺណែវ ថ្ងៃទី ១៣ ខែ កក្កដា ១៩៣១.

(ង) កិច្ចព្រមព្រៀងសំរាប់ការត្រួតពិនិត្យការជក់អាភៀននៅចុងបូពាំ បានចុះហត្ថលេខានៅទីក្រុង បាងកក នាថ្ងៃទី ២៧ ខែ វិច្ឆិកា ១៩៣១.

(ច) ពិធីសារចុះហត្ថលេខានៅ លេកសាក់សេស (Lake Success)នៅថ្ងៃទី ១១ ធ្នូ ១៩៤៦ ដោយធ្វើវិសោធនកម្ម លើកិច្ចព្រមព្រៀង អនុសញ្ញា និង កិច្ចសារលើគ្រឿងញៀនដែលធ្វើឡើងនៅទីក្រុងឡាអេ ថ្ងៃទី ២៣ មករា ១៩១២. នៅទីក្រុងហ្សឺណែវ ថ្ងៃទី ១១ កុម្ភៈ ១៩២៥. និង ១៩ កុម្ភៈ ១៩២៥. និង ១៣ កក្កដា ១៩៣១ នៅទីក្រុងបាងកកថ្ងៃទី ២៧ វិច្ឆិកា ១៩៣១. និង

នៅទីក្រុងហ្សឺណែវ ថ្ងៃទី ២៦ មិថុនា ១៩៣៦ លើកលែងតែវា ប៉ះពាល់ដល់អនុសញ្ញាដែលដាក់ឈ្មោះចុងក្រោយ.

(ឆ) អនុសញ្ញា និងកិច្ចព្រមព្រៀងដែលមានយោងក្នុងអនុកថាខ័ណ្ឌ (ក) ដល់ (ង) ដូចបានធ្វើវិសោធនកម្ម ដោយពិធីសារនៃឆ្នាំ ១៩៤៦ ដូចមានយោងក្នុងអនុកថាខ័ណ្ឌ (ច).

(ជ) ពិធីសារ បានចុះហត្ថលេខានៅទីក្រុងប៉ារីស ថ្ងៃទី ១៩ វិច្ឆិកា ១៩៤៨ ដោយដាក់បញ្ចូលក្រោមការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ក្រោវិសាលភាពនៃអនុសញ្ញា ចុះថ្ងៃទី ១៣ កក្កដា ១៩៣១ សំរាប់ការដាក់កិរិតលើការផលិតនិងការគ្រប់គ្រងការចែកចាយគ្រឿងញៀនដូចបានធ្វើវិសោធនកម្ម ដោយ ពិធីសារ ដែលបានចុះហត្ថលេខានៅ លេកសាក់សេស នៅថ្ងៃទី ១១ ធ្នូ ១៩៤៦.

(ឈ) ពិធីសារសំរាប់ការកំរិត និងការដាក់បទបញ្ជាលើការដាំដុះដើមអាភៀន ការផលិត ការធ្វើជំនួញជាអន្តរជាតិ និងការលក់ដុំ និងការប្រើប្រាស់អាភៀន បានចុះហត្ថលេខានៅទីក្រុងញ៉ូយក នាថ្ងៃទី ២៣ មិថុនា ១៩៥៣ គួរតែពិធីសារនោះ បានចូលជាធរមាន ។

